ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង

Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 04-Sep-2012, 16:09
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

# ជំនុំជម្រះក្តីនៅដំណាក់កាលដំបូង

## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសជ

**ថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០១២**

**ម៉ោង ០៩:០២ នាទី**

**សវនាការលើកទី១០៦**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍

*(Judge Silvia Cartwright)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍

*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ក្លូឌា ហ្វេនស៍ (បម្រុង)

*(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ដាវ អានសាន

លោកស្រី សែ កុលវុឌ្ឍី

កញ្ញា ណាតាចា វីស៊ែល រីស៊ើ

*(Ms. Natacha WEXELS-RISER)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក វ៉េង ហ៊ត់

លោក ច័ន្ទ តារាវស្ធី

លោក ថារីក អាប់ឌុលឡាក់

*(Mr. Tarik ABDULHAK)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

លោក អៀង សារី

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក អេនឌ្រូ អ៊ីនូហ្ស៊ី *(Mr. Andrew IANUZZI)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

លោក អាកទួរ វែកកែន

*(Mr. Arthur VERCKEN)*

**មេធាវីការពារជនជាប់ចោទ អៀង សារី៖**

លោក អាង ឧត្តម

លោក ម៉ៃខល កាណាវាស

*(Mr.Michael KARNAVAS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត

*(Ms. Elisabeth SIMONNEAU-FORT)*

លោក ឡោ ជុនធី

លោក វ៉ែន ពៅ

លោកស្រី ទី ស្រីនណា

កញ្ញា ហ្វីលីពីន ស៊ុតហ្ស៍

*(Ms. Philipine SUTZ)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណ

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| លោក អាប់ឌុលឡាក់ ថារីក | អង់គ្លេស |
| លោក ម៉ៃខល កាណាវាស | អង់គ្លេស |
| លោក ពេជ អង្គ | ខ្មែរ |
| លោកស្រី ទី ស្រ៊ីនណា | ខ្មែរ |
| កញ្ញា ហ្វីលីពីន ស៊ុតហ្ស៍ | បារាំង |
| លោក នង សុផង់ (TCW-480) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី៖ លោក នន សុផល់** (TCW-480)


សួរបន្តដោយលោក អាប់ឌុលឡាក់ ថារីក ផ្តើមពី៖........................................................ទំព័រ ៤
សួរដោយលោកស្រី ទី ស្រ៊ីនណា ផ្តើមពី៖..................................................................ទំព័រ ១៩
សួរដោយកញ្ញា ហ្វីលីពីន ស៊ុតហ្ស៍ ផ្តើមពី៖ ..............................................................ទំព័រ ៣៦

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០២:៥១]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ នៅក្នុងកិច្ចដំណើរការសវនាការនៅព្រឹកនេះ អង្គជំនុំជម្រះនឹងបន្តស្ដាប់សក្ខីកម្មសាក្សី នង សុផង់ ដែលនឹងសួរដេញដោលដោយតំណាងសហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី។ ហើយថ្ងៃនេះក៏ជម្រាបផងដែរថា លោកស្រីចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍ មានលទ្ធភាពអាចចូលរួមនៅក្នុងកិច្ចដំណើរការសវនាការបានវិញហើយ។ ហើយមុននឹងចាប់ប្រគល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា សូមលោកស្រី សែ កុលវុឌ្ឍី ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមាន ភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការនេះ។

[០៩:០៤:២១]

**ក្រឡាបញ្ជី៖**

*(មីក្រូហ្វូនមិនទាន់ដំណើរការ)*

... ខាងក្រោមបន្ទប់សវនាការ ដោយជនជាប់ចោទស្នើសុំលះបង់សិទ្ធិ--

សូមគោរពលោកប្រធាន គ្រប់ភាគីទាំងអស់នៅក្នុងរឿងក្ដីនេះមានវត្តមាន។ លើកលែងតែជនជាប់ចោទ អៀង សារី មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមបន្ទប់សវនាការ ដោយជនជាប់ចោទស្នើសុំលះបង់សិទ្ធិតាមរយៈមេធាវីរបស់គាត់ក្នុងការចូលរួមដំណើរការនីតិវិធីដោយផ្ទាល់ ពីបន្ទប់សវនាការសម្រាប់រយៈពេលពេញ១ថ្ងៃ នៃថ្ងៃសវនាការនេះ។ លិខិតលះបង់សិទ្ធិរបស់ជនជាប់ចោទបានប្រគល់ក្រឡាបញ្ជីរួចហើយ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ អង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់ជនជាប់ចោទ អៀង សារី។ អង្គជំនុំជម្រះបានទទួលពាក្យសុំរបស់ជនជាប់ចោទ អៀង សារី ចុះថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០១២ តាមរយៈមេធាវីការពារក្ដីរបស់គាត់ សុំលះបង់សិទ្ធិមានវត្តមានក្នុងបន្ទប់សវនាការនេះ ដោយសុំនៅតាមដានកិច្ច

E1/121.1

ដំណើរការសវនាការពីចម្ងាយ តាមរយៈប្រព័ន្ធសោតទស្សន៍ សម្រាប់រយៈពេលដំណើរការសវនាការសម្រាប់ព្រឹកនេះ។ វេជ្ជបណ្ឌិត ស្វួស សែម គ្រូពេទ្យទទួលពិនិត្យព្យាបាលថែទាំសុខភាពជនជាប់ចោទនៅមន្ទីរឃុំឃាំងនៃ អ.វ.ត.ក បានពិនិត្យសុខភាពលោក អៀង សារី នៅព្រឹកនេះ ហើយបានកត់សម្គាល់ឃើញថា លោក អៀង សារី មានអាការៈវិលមុខពេលក្រោកឈរ ហត់ពេលធ្វើចលនា អស់កម្លាំងអង្គុយមិនបានយូរ ដោយឈឺចង្កេះនិងឈឺខ្នង និងបានផ្តល់អនុសាសន៍ថា អង្គជំនុំជម្រះគួរអនុញ្ញាតឲ្យគាត់នៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ខាងក្រោម។

[០៩:០៦:០៧]

នៅពេលនេះលោក អៀង សារី បានលះបង់សិទ្ធិចូលរួមក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ។ គាត់មានបញ្ហាសុខភាព ដូចគ្រូពេទ្យបានកត់សម្គាល់ តែរូបកាយនិងស្មារតីសមស្រប គាត់អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅខាងក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍ ហើយអាចសម្រួលទំនាក់ទំនងរវាងគាត់ជាមួយនឹងក្រុមមេធាវីការពារក្តីរបស់គាត់បានដែរ។

អង្គជំនុំជម្រះសម្រេចយល់ព្រមតាមសំណើសុំរបស់ជនជាប់ចោទ អៀង សារី ដែលសុំលះបង់សិទ្ធិចូលរួមក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់ នៅក្នុងបន្ទប់សវនាការនេះ។ ឲ្យលោក អៀង សារី នៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍ សម្រាប់រយៈពេលដំណើរការសវនាការពេញមួយព្រឹកនេះ។

បង្គាប់ឲ្យបុគ្គលិកផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់លោក អៀង សារី អាចតាមដានកិច្ចដំណើរការសវនាការពីចម្ងាយសម្រាប់រយៈពេលធ្វើសវនាការពេញមួយព្រឹកនេះ។

[០៩:០៧:០៦]

**ប្រធានអង្គជំនុំ៖**

លោក នង សុផង់ តាមព័ត៌មានដែលយើងទទួលបានអម្បាញ់មិញនេះថា លោកមានអាការៈមិនសូវស្រួលខ្លួន ដោយសារសម្ពាធឈាមរបស់លោកឡើងខុសពីធម្មតា។ អ៊ីចឹងពិតមែនទេ?

**លោក នង សុផង់៖**

បាទ ជម្រាបលោកប្រធានពិតដូច្នោះមែនបាទ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ ដោយលោកប្តេជ្ញាចិត្តក្នុងការប្រឹងប្រែងក្នុងការផ្តល់សក្ខីកម្មតាមកាលបរិច្ឆេទការកំណត់នឹងធ្វើសវនាការរបស់អង្គជំនុំជម្រះ។ ប៉ុន្តែនៅព្រឹកនេះប្រសិនបើលោកប្រមើលមើល៍នូវបញ្ហាសុខភាពរបស់លោកនៅពេលណាមួយ ប្រសិនបើទំនងជាអាចមានបញ្ហាទៅមិនរួចទេ គឺលោកជាបន្ទាប់កុំរារែកគឺលើកដៃ ហើយសុំយើងដើម្បីសម្រាក។ អាចសម្រាកជាបណ្តោះអាសន្ន ឬក៏សម្រាកតែម្តងក៏បានដែរ អាស្រ័យលើស្ថានភាពជាក់ស្តែងណា៎ះ។

**លោក នង សុផង់៖**

បាទ សូមអរគុណបាទ។

[០៩:០៨:១៩]

**ប្រធានអង្គជំនុំ៖**

បាទ ជាបន្តអង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញាដើម្បីបន្តការតាំងសំណួរចំពោះសាក្សី។

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន។ សូមជម្រាបសួរអស់លោក លោកស្រីចៅក្រម។ សូមជម្រាបសួរលោកមេធាវី និងភាគីទាំងអស់ ហើយជាពិសេសសូមជម្រាបសួរលោកសាក្សី។

នៅក្នុងដំណាក់កាលចុងក្រោយនៃការសាកសួររបស់ខ្ញុំនៅពេលនេះ ខ្ញុំចង់ពិនិត្យទៅលើឯកសារបន្ថែមពីរបីទៀត។ ហើយឯកសារទី១ គឺជាទូរលេខ ហើយជាទូរលេខចុងក្រោយដែលយើងពិនិត្យទាំងអស់គ្នា។ ឯកសារនោះគឺមានលេខ E3 គឺ E3/1077 ដែលជាឯកសារភ្ជាប់ជាមួយចម្លើយសាររបស់សាក្សី។

ខ្ញុំមានឯកសារជាក្រដាស ហើយខ្ញុំសូមអនុញ្ញាតលោកប្រធានមេត្តាប្រគល់ជូនទៅសាក្សី ហើយសូមលោកប្រធានអនុញ្ញាតឲ្យបង្ហាញនៅលើអេក្រង់ទូរទស្សន៍ និងកុំព្យូទ័រ។

[០៩:០៩:៣១]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត! មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារពីតំណាងសហព្រះរាជអាជ្ញាយកជូនសាក្សីពិនិត្យ!

*(មន្ត្រីតុលាការយកឯកសារជូនសាក្សី)*

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរបន្តដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** លោក សុផង់ ជាកិច្ចផ្ដើម នេះគឺជាឯកសារដែលមានទំហំវែង ហើយឯកសារនេះ ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ៧៨ ហើយឯកសារនេះ មានចំណងជើងថា “ពីរបីបួន គឺទូរលេខ៣២៤” ហើយដាក់ថា “គោរពជូនគណៈ៨៧០ ជាទីស្នេហា”។ លោក សុផង់ សូមលោកពិនិត្យមើលទៅលើទំព័រចុងក្រោយ គឺនៅផ្នែកខាងក្រោយនៃឯកសារ សូមលោកពិនិត្យមើលបន្តិច គឺនៅក្រោមកាលបរិច្ឆេទ គឺនៅថ្ងៃ១០ មេសា ១៩៧៨ គឺយើងឃើញឈ្មោះមួយ ដែលសរសេរថា -- តើលោកស្គាល់ទេ “ឈ្មោះ សែ” ហ្នឹង អ្នកណាដែរ?

[០៩:១១:១៥]

**លោក នង សុផង់៖**

**ផ៖** បាទ ខ្ញុំអត់ស្គាល់ទេបាទ។

**ស៖** ហើយនៅក្រោមឈ្មោះ សែ នោះ គឺមានជួរមួយ ដែលសរសេរទទួល ថ្ងៃ១១ ខែមេសា ឆ្នាំ១៩៧៨។ ហើយយើងឃើញដាក់ថា “អ៊ំ, អ៊ំនួន, អ៊ំវ៉ាន់, អ៊ំវន, មន្ទីរ និងឯកសារ”។ នេះ គឺជាផ្នែកចម្លងជូន ដូចឯកសារដទៃទៀតដែរ ហើយនៅទំព័រទី១ យើងឃើញនូវចំណារនៅលើផ្នែកខាងឆ្វេងបំផុត ដែលចំណារនេះ សរសេរថា “អ៊ំ នួន” តើលោកឃើញចំណារនេះដែរឬទេ? ហើយតើលោកបានមើលទេ ឃើញថា អ៊ំ នួន ដូចខ្ញុំដែរឬទេ?

**ផ៖** បាទ បានឃើញ ដូចលោកបានអានដែរ បាទ។

**ស៖** តើលោកអាចបញ្ជាក់បានទេ ថាអក្សរសរសេរដៃហ្នឹង ជាអក្សររបស់អ្នកណាដែរ?

**ផ៖** ជាអក្សរ -- ក្នុងចម្លើយខ្ញុំដាក់ថាម៉េច ខ្ញុំសូមឲ្យលោកអានចម្លើយដែលលោកចៅក្រមស៊ើបអង្កេតណា៎។ មិនសូវច្បាស់ បាទ។

**ស៖** ខ្ញុំសូមអភ័យទោស នៅក្នុងករណីមួយនេះមិនមានការពិភាក្សាលម្អិត នៅក្នុងសេចក្ដីសង្ខេបចម្លើយ ការស្ដាប់ចម្លើយសាក្សីរបស់លោកនោះទេ។ ប្រសិនបើលោកមិនប្រាកដអំពីអក្សរនេះទេ

គឺលោកឆ្លើយតាមហ្នឹងទៅ គឺមិនមានបញ្ហាអ្វីនោះទេ សូមលោកជម្រាបផង។

**ឆ៖** បាទ អរគុណ បាទ។

[០៩:១៣:៥៥]

**ស៖** សូមលោកពិនិត្យទៅលើខ្លឹមសារបន្តិច គឺនៅទំព័រទី១ នៅក្នុងភាសា -- ទាំងបីភាសានោះ គឺយើងបានដាក់នូវការ៉េ បន្ទាត់ការ៉េហ៊ុំជុំវិញខ្លឹមសារ ដែលខ្ញុំចង់ពិភាក្សានោះ។ នៅមុនអាបន្ទាត់ក្រហមហ្នឹង គឺយើងនិយាយអំពីស្ថានភាពខ្មាំងតាមព្រំដែនថៃ និងលាវ ហើយនៅក្នុងប្រអប់នោះ មានសរសេរដូចតទៅ៖ "ទីតាំងពួកអាក្បត់ទាំងនេះ នៅភ្នំដងរែក។ យើងក៏បានវិធានការរកទីតាំងរបស់វា ដើម្បីវាយកម្ទេចវា។ ពួកអា អ៊ិន តាំ កាលពីមុន វាយកពួកអាក្បត់នៅតំបន់១០៣ ដែលអា ហង្ស ជាមេ ដើម្បីធ្វើជាបង្អែកវា។ តែក្រោយពីយើងចាប់ អាហង្ស និងដៃជើងវា នៅក្នុងផ្សារ នៅក្នុងស្រុកជាំក្សាន្ត និងនៅកងទ័ពតំបន់១០៣ មក ពួកអា អ៊ិន តាំ ត្រូវអស់បង្អែក"។ នៅពេលដែលលោកពិនិត្យមើលទៅលើឈ្មោះ ហង្ស មកពីតំបន់១០៣ហ្នឹង តើឈ្មោះ ហង្ស ហ្នឹងគឺដូចជាឈ្មោះ ហង្ស ដែលជាលេខាតំបន់ ១០៣ ដែលយើងបានពិភាក្សាកាលពីពេលមុនដែរឬទេ? តើជាមនុស្សតែមួយដែរឬទេ?

**ឆ៖** បាទ ហង្ស នេះគឺជាមនុស្សតែមួយបាទ។

**ស៖** សូមអរគុណលោក។ ខ្ញុំសូមបង្ហាញនូវទូរលេខមួយទៀត មកពីទីតាំងតែមួយ ហើយខ្ញុំនឹងសាកសួរដើម្បីឲ្យលោកបង្ហាញថាលោកស្គាល់ឬក៏អត់។ នេះគឺជាឯកសារ E3/918 គឺចុះថ្ងៃទី១០ ខែមករា ឆ្នាំ១៩៧៨។

**លោក អាប់ឌុលឡាក់ ថារីក៖**

ខ្ញុំមានឯកសារជាក្រដាស ហើយខ្ញុំសូមអនុញ្ញាតលោកប្រធានបង្ហាញនៅលើអេក្រង់ទូរទស្សន៍ និងកុំព្យូទ័រ។

[០៩:១៦:១៣]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** ឯកសារនេះគឺចម្លងជូនអ៊ំ នួន, អ៊ំ, បងវ៉ាន់, បងវន, បងខៀវ, មន្ទីរ និងឯកសារ។ គឺឯកសារនេះដាក់ថា "គោរពជូនមន្ទីរ៨៧០"។ នៅពេលដែលលោកពិនិត្យទៅលើឯកសារនេះ លោក

សុផង់ តើនេះជាទូរលេខដែលចាំថា លោកធ្លាប់បកប្រែនៅក្នុងឆ្នាំ១៩៧៨ តើលោកចាំថាលោកធ្លាប់បកប្រែទូរលេខនេះដែរឬទេ?

**លោក នង សុផង់៖**

**ផ៖** បាទ ខ្ញុំចាំថាទិសនេះជាភូមិភាគមួយដែលរៀបចំថ្មីបាទ។ គឺក្រោយពីខាងតំបន់ស្វយ័តសៀមរាប ឧត្តមានជ័យ និងព្រះវិហារ បានលុបចេញ ហើយក៏បង្កើតភូមិភាគមួយថ្មីហៅថា “ភូមិភាគ៨០១” បាទ។ អ៊ីចឹងទិសនេះគឺក្រុមខ្ញុំ និងគ្រូខ្ញុំគាត់ធ្លាប់បានបកប្រែបាទ។

[០៩:១៨:០១]

**ស៖** ប្រសិនបើយើងពិនិត្យមើលទៅលើកថាខណ្ឌមួយ គឺកថាខណ្ឌទី២ ពីខាងក្រោម គឺមានលេខ ERN ភាសាខ្មែរ 00001061 ដល់ 62, ភាសាបារាំងគឺមានលេខ 0064725 (ស៊ីក), ហើយភាសាអង់គ្លេសគឺមានលេខ 00182758។ យើងបានឃើញអំពីការពិភាក្សាអំពីវគ្គរៀនសូត្រ ដែលសរសេរដូចតទៅ។ ខ្ញុំសូមអាន “យោងតាមការបង្ហាញរបស់សមមិត្តមកពីឃុំនៅក្នុងវគ្គសិក្សា គឺមានការបង្ហាញថា ឆ្នាំនេះនៅក្នុងខាងព្រះវិហារ ភាគច្រើនគឺមានការអត់ឃ្លាន ពីព្រោះមានការដាំដុះច្រើនប៉ុន្តែមិនមានគុណភាពនោះឡើយ។ ដូច្នេះហើយទើបវាមិនទទួលបានផលនៅពេលប្រមូលផល”។ ខ្ញុំចង់សួរលោកទៅលើកថាខណ្ឌនេះ ថាតើលោកចាំដែរឬទេ អំពីខ្លឹមសារ ឬក៏អំពីអត្ថន័យនៃការទាក់ទងដែលគេនិយាយអំពីការខ្វះខាតនូវស្បៀងអាហារ ឬក៏ការខ្វះខាតនូវស្រូវ អង្ករហ្នឹង តើលោកចាំដែរឬទេ?

[០៩:១៩:៣៨]

**ផ៖** បាទ ទូរលេខខ្ញុំនេះ ដូចមិនមានខ្លឹមសារដូចលោកបានអានទេ។ សូម្បីតែក្បាលក៏ខុសគ្នា។ នេះគឺ “គោរពជូនគណៈ៨៧០” តែលោកអានថា “ជូនមន្ទីរ៨៧០”។ ដូច្នេះគឺខ្លឹមសារដូចមិនស៊ីគ្នានឹងលោកអានសោះ។ ហើយខ្ញុំអត់មានឃើញខ្លឹមសារដែលលោកអានអំមិញទេ។

**ស៖** ប្រហែលជាខ្ញុំអានពីផ្នែកផ្សេង ហើយលោកមើលនៅផ្នែកផ្សេង ដូច្នេះ ខ្ញុំស្នើសុំឲ្យមន្ត្រីតុលាការជួយ។ នៅក្នុងភាសាខ្មែរ គឺកថាខណ្ឌដែលចាប់ផ្តើមនៅទំព័រចុងក្រោយ ហើយយើងចាប់ផ្តើមមើលទៅលើ -- ដូច្នេះស្នើសុំឲ្យជួយបញ្ជាក់ថា តើយើងមានឯកសារត្រូវដូចគ្នាដែរឬមួយក៏យ៉ាងណា? ដូច្នេះ ក្នុងភាសាអង់គ្លេស គឺចាប់ផ្តើមអំពីការនិយាយថា “គោក្របីត្រូវបានសម្លាប់ ត្រូវបានងាប់ដោយសារបញ្ហាផ្សេងៗ”។ បន្ទាប់មកបើសិនជាលោកមើលទៅបន្ត គឺមានការពិភាក្សាអំពីកង្វះខាតដូចដែលខ្ញុំបានអានជូនលោកស្តាប់អម្បាញ់មិញនេះ។

[០៩:២១:៣៦]

ខាងមន្ត្រីតុលាការបានជម្រាបប្រាប់ខ្ញុំថា ឯកសារហ្នឹងដូចគ្នា ប៉ុន្តែដើម្បីកុំឲ្យចំណាយពេលឥតប្រយោជន៍ ខ្ញុំសូមសួរជាទូទៅ ថាតើលោកចាំដែរឬទេថា មានការរាយការណ៍ពីភូមិភាគពាយ័ព្យដែលនិយាយពីខ្វះខាតស្បៀងអាហារហ្នឹង តើលោកចាំដែរឬទេ?

**ឆ៖** បាទ ខ្ញុំបានឃើញសារទូរលេខមុនៗនិយាយអំពីរឿងបង្កបង្កើនផលបានច្រើន ប៉ុន្តែលើកនេះគឺឃើញថា មានកង្វះខាត។ ដូច្នេះ គឺប្រហែលជាការខ្វះខាតវាមានដោយកន្លែងបាទ ពិសេសគឺនៅតំបន់ព្រះវិហារតែម្តងបាទ។

**សះ** សូមអរគុណ។ យើងនឹងបញ្ចប់ឯកសារមួយនេះ ហើយយើងបញ្ចប់ការពិភាក្សាទៅលើបញ្ហាទូរលេខ ហើយចុងក្រោយខ្ញុំចង់សួរលោកជាទូទៅពាក់ព័ន្ធទៅនឹងបញ្ហាសារទូរលេខក្នុងរយៈពេល ២-៣ថ្ងៃកន្លងមក គឺយើងបានពិនិត្យមើលទៅលើទូរលេខមួយចំនួនដែលលោកបានពិនិត្យ។ តាមបទពិសោធន៍ផ្ទាល់ខ្លួនរបស់លោក នៅពេលដែលលោកបំពេញការងារពាក់ព័ន្ធទៅនឹងទូរលេខពីឆ្នាំ៧៥ ដល់ ៧៩ តើឯកសារទាំងអស់នេះ គឺវាជាឯកសារដែលលោកមើលទៅថាវាជាឯកសារពិតប្រាកដ ឯកសារត្រឹមត្រូវដែលបានធ្វើឡើងនៅក្នុងឆ្នាំ -- នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យដែរឬទេ?

[០៩:២៣:៤៨]

**ឆ៖** បាទ ទូរលេខដែលខ្ញុំបានពិនិត្យ ដែលបានឃើញដោយផ្ទាល់នៅក្នុងអង្គសវនាការទាំងអស់នេះ គឺពិតជាខ្លឹមសារដែលខ្ញុំ និងក្រុមយើងខ្ញុំបានបកប្រែមែន លើកលែងតែខ្លឹមសារមួយដែលដាក់ថាជូនម-៨១ ហ្នឹងវាដូចជាខ្ញុំមិនដែលឃើញបាទ។ មិនមែនជាក្រុមរបស់ខ្ញុំបកបាទ។ ឯក្រៅពីហ្នឹង គឺខ្ញុំបានកត់សម្គាល់ឃើញថា សុទ្ធតែជាសារទូរលេខដែលខ្ញុំ និងក្រុមខ្ញុំបានបកប្រែបាទ។

**សះ** សូមអរគុណ។ ដូច្នេះ ខ្ញុំសូមបញ្ចប់ការពិភាក្សាអំពីទូរលេខ ខ្ញុំនឹងបន្តទៅប្រធានបទថ្មីមួយទៀត។ ហើយយើងអាចនឹងពិភាក្សាឲ្យបានឆាប់រហ័សទៅលើបញ្ហាបន្ត។ កាលពីម្សិលមិញ ខ្ញុំស្នើសូមឲ្យមានការបង្ហាញ គឺស្នើសុំអាននូវឯកសារមួយគឺឯកសារហ្វីប៊ីស ដែលជាប្រតិចារឹក ប៉ុន្តែឯកសារហ្នឹងមិនទាន់បានដាក់បង្ហាញនៅក្នុង អ៊ីនធីហ្វេស ប៉ុន្តែអង្គជំនុំជម្រះបានស្នើឲ្យយើងដាក់បង្ហាញនូវឯកសារហ្នឹងទៅក្នុងអ៊ីនធីហ្វេស ដើម្បីឲ្យភាគីបានដឹង។ ដូច្នេះ ឥឡូវយើងបានធ្វើតាមនេះហើយ ហើយឯកសារនេះគឺមានលេខ E3/118 ហើយគឺនៅខែមេសា ឆ្នាំ១៩៧៥ ជាឯកសារ ហ្វីប៊ីស គឺចុះថ្ងៃទី ១៨ -- ១៧ មេសា ១៩៧៥។ ដូចដែលខ្ញុំបានបញ្ជាក់ពីម្សិលមិញអ៊ីចឹង គឺយើងមិនមានឯកសារជាភាសាខ្មែរ និង

ភាសាបារាំងនោះទេ។ ប៉ុន្តែយ៉ាងណាក៏ដោយខាងព្រះរាជអាជ្ញាបានស្នើសុំឲ្យមានការបកប្រែរួចហើយ។

[០៩:២៦:០៧]

**លោក អាប់ឌុលឡាក់ ថារីក៖**

ប្រសិនបើលោកប្រធានអនុញ្ញាត គឺខ្ញុំសូមថាអាននូវការដកស្រង់មួយចំនួន ពីឯកសារនេះ ដើម្បីឲ្យសាក្សីស្តាប់ ហើយឯកសារនេះនិយាយអំពីជោគជ័យថ្ងៃ១៧ មេសា ១៩៧៥។ ហើយអាចនឹងៗរៀបរាប់ពីសារដែលសាក្សីគាត់ប្រហែលជាបានរៀបចំដើម្បីធ្វើការផ្សព្វផ្សាយ។ សូមលោកប្រធានអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** គឺមានERN 00166976 ខ្ញុំសូមធ្វើការបង្ហាញ គឺថានៅថ្ងៃ២៩ ខែ៨ លោកបានិយាយអំពីសារមួយដែលគេបានបញ្ជូននៅពេលព្រឹក នៅថ្ងៃ១៧ មេសា ៧៥ វាមិនមែនជាសារសម្ងាត់នោះទេ។ ហើយគេស្នើឲ្យលោកធ្វើការរៀបចំ ដើម្បីបកប្រែសារនោះទៅជាឯកសារសរសេរ ហើយដើម្បីយកមកផ្សព្វផ្សាយ។ ខ្ញុំសូមអាននូវប្រតិចារឹកនេះ ដើម្បីពិនិត្យមើលថាតើលោកចាំថាតើ សារដែលខ្ញុំអានហ្នឹងគឺជាសារដែលលោកបានធ្វើការរៀបចំហ្នឹង ឬមួយក៏យ៉ាងណា? នេះគឺជាការផ្សព្វផ្សាយដោយសំឡេងវណសិរ្សរួបរួមជាតិកម្ពុជា គឺជាភាសាខ្មែរ នៅថ្ងៃ១៧ មេសា ១៩៧៥ ហើយអត្ថបទហ្នឹងរៀបរាប់ដូចតទៅ ខ្ញុំសូមដកស្រង់៖ “ព័ត៌មានពិសេស យើងបានបញ្ចប់ការរំដោះទីក្រុងភ្នំពេញនៅព្រឹកថ្ងៃ១៧ មេសា ១៩៧៥ នៅម៉ោងប្រាំបួនសាមសិប។ នៅម៉ោងប្រាំបួនសាមសិប យើងបានរំដោះភ្នំពេញទាំងស្រុង”។

[០៩:២៨:១៤]

ហើយបន្ទាប់មកនៅកថាខណ្ឌបន្ទាប់បានរៀបរាប់ថា “នៅសមរភូមិខាងជើង គឺយើងបានស្ថិតនៅលើស្ពានជ្រោយចង្វារ ហើយបានគ្រប់គ្រងតំបន់វត្តភ្នំនៅពេលព្រឹកថ្ងៃ១៧ មេសា ហើយបន្ទាប់មកយើងបានបន្តទៅកាន់កាប់ផ្សារថ្មីនិងផ្សារចាស់។ នៅខាងពាយ័ព្យ នៅយប់ថ្ងៃ១៦ មេសា យើងគ្រប់គ្រងតំបន់ទួលគោក ហើយនៅព្រឹក១៧ មេសា គឺយើងបានវាយសម្រុកមកមុខ ហើយកាន់កាប់ស្ថានីយរថភ្លើងភ្នំពេញទាំងស្រុង ហើយព្រមទាំងគ្រប់គ្រងតំបន់ក្រសួងនៅខាងត្បូងនៃស្ថានីយរថភ្លើង”។ ហើយបានបន្តរៀបរាប់ពីការគ្រប់គ្រងទីក្រុងភ្នំពេញ។ តាមអ្វីដែលខ្ញុំបានអានកន្លងមកនេះ លោក សុផង់ តើអត្ថបទនេះ វាដូចគ្នានឹងសារដែលលោកបានទទួលនៅថ្ងៃ១៧ មេសា ៧៥ ហើយដែលលោកយកមក

ធ្វើការផ្សព្វផ្សាយហ្នឹង តើវាដូចគ្នា ឬមួយក៏មិនដូចទេ?

[០៩:២៩:២៩]

**លោក នង សុផង់៖**

**ឆ៖** បាទ ដូចគ្នាបាទ។

**ស៖** សូមអរគុណ។ ខ្ញុំសូមសួរលោកថា តើលោកចាំដែរឬទេ ថាអ្នកណាជាអ្នកបញ្ជូនសារនេះមកឲ្យលោក?

**ឆ៖** បាទគឺ ក្រុមលោក ប៉ុន ដែលគាត់នៅប្រចាំការនៅសមរភូមិបានធ្វើសារនេះឲ្យយើងខ្ញុំដែលជាអ្នកទទួលនៅសមរភូមិក្រោយនេះបាទ ដើម្បីរៀបចំផ្សាយវិទ្យុបាទ។

**ស៖** ហើយក្រៅពីសារនៅថ្ងៃ១៧ មេសា ៧៥ នេះ ថាតើលោកបានទទួលនូវសារផ្សេងៗទៀតសម្រាប់ធ្វើការផ្សព្វផ្សាយជាសារធារណៈ នៅក្រោយថ្ងៃ១៧ មេសា ៧៥ ដែរឬទេ?

[០៩:៣០:៤៩]

**ឆ៖** បាទ មិនមានទេ បាទ។ ខ្លឹមសារនោះ គេផ្សាយដដែលៗពីរបីថ្ងៃឯណោះ។

**ស៖** សូមអរគុណ។ ហើយការផ្សព្វផ្សាយមួយចុងក្រោយ ដែលខ្ញុំចង់ពិភាក្សាផងដែរ គឺខ្ញុំសូមត្រឡប់ក្រោយបន្តិចទៅខែកុម្ភៈ ឆ្នាំ៧៥ ដើម្បីពិនិត្យមើលថាតើលោកចាំ អំពីការផ្សព្វផ្សាយនេះដែរឬទេ?

**លោក អាប់ឌុលឡាក់ ថារីក៖**

លោកប្រធាន នេះគឺឯកសារ E3/117 គឺចុះខែកុម្ភៈ ឆ្នាំ៧៥ ជាឯកសារ ហ្វីប៊ីស ហើយផ្នែកដែលខ្ញុំចង់និយាយយោងទៅលើហ្នឹងគឺមាន នៅត្រង់ ERN 00242808, ហើយភាសាបារាំងគឺមាន 00281432, ហើយភាសាអង់គ្លេសគឺ 0060667 (ស៊ីក)។ ខ្ញុំមានឯកសារជាក្រដាស ហើយវាជាឯកសារការផ្សព្វផ្សាយ ប្រសិនបើថា លោកប្រធានមិនឲ្យផ្តល់ឯកសារជាក្រដាសទេ ខ្ញុំនឹងអានជូនសាក្សីស្តាប់។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត! មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារក្រដាសពីសាក្សី -- អ៎ ពីតំណាងសហព្រះរាជអាជ្ញាយកជូនសាក្សីពិនិត្យ!

*(មន្ត្រីតុលាការយកឯកសារជូនសាក្សី)*

[០៩:៣២:៣៥]

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** លោក សុផង់ នេះគឺជាឯកសារបកប្រែទៅជាភាសាខ្មែរ។ ដូច្នេះវាមិនមែនជាឯកសារដើមរបស់កម្ពុជាប្រជាធិបតេយ្យ គឺមិនមែនជាឯកសារពីឆ្នាំ៧៥ នោះទេ។ វាគឺជាប្រតិចារឹកនៃការផ្សព្វផ្សាយតាមវិទ្យុម្តងទៀត ហើយខ្ញុំចង់ជម្រាបសាកសួរលោក ថាតើលោកចាំដែរឬទេ? ហើយនេះគឺជាវិទ្យុផ្សាយសំឡេងរណសិរ្សរួបរួមជាតិកម្ពុជា ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ១៩៧៥។ ហើយវាជាអត្ថបទសេចក្តីថ្លែងការណ៍ព័ត៌មានចុះថ្ងៃទី២៦ ខែកុម្ភៈ ស្តីពីសម័យប្រជុំលើកទី២ ពីថ្ងៃទី២៤-២៥ ខែកុម្ភៈ របស់សមាជជាតិដែលបានប្រារព្ធធ្វើដោយតំណាង នៃរណសិរ្សរួបរួមជាតិនៃកម្ពុជា និងអង្គការមហាជន។ ហើយនៅក្នុងកថាខណ្ឌទី១ គឺបានសរសេរដូចទៅនេះ ខ្ញុំសូមដកស្រង់៖ “ពាក់ព័ន្ធទៅនឹងជនក្បត់ទាំងប្រាំពីរ រណសិរ្សរួបរួមជាតិកម្ពុជា បានសម្រេចដូចតទៅ៖ លន់ នល់, សិរិមតៈ, សឺង ង៉ុកថាញ់, ចេង ហេង, អ៊ិន តាំ, ឡុង បូរ៉េត និង ស្វស្តែន ហ្វែណង់ដេស គឺជាប្រមុខពួកក្បត់ និងជាប្រធានក្រុមធ្វើរដ្ឋប្រហារប្រឆាំងជាតិដ៏ទុរយស ដែលបានផ្តួលរំលំឯករាជ្យ សន្តិភាព និងអព្យាក្រឹត្យរបស់កម្ពុជា”។

[០៩:៣៤:១៨]

ហើយចុះក្រោមបន្តិច “ក្នុងនាមរណសិរ្សរួបរួមជាតិកម្ពុជា រាជរដ្ឋាភិបាលបង្រួបបង្រួមជាតិកម្ពុជា និងកងកម្លាំងប្រដាប់អាវុធរំដោះជាតិកម្ពុជា សមាជជាតិបានប្រកាសថា វាជាការចាំបាច់ជាដាច់ខាតត្រូវសម្លាប់ជនក្បត់ទាំងប្រាំពីរនាក់នេះ ចំពោះអំពើក្បត់ជាតិរបស់ពួកវា ដែលប្រឆាំងនឹងប្រជាជាតិ”។ ខ្ញុំសូមបញ្ចប់ត្រង់ចំណុចនេះ។ តើលោកចាំអំពីការផ្សព្វផ្សាយបែបនេះដែរឬទេ គឺចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ១៩៧៥? តើលោកចាំថាមានការផ្សព្វផ្សាយបែបនេះទេ?

**ឆ៖** បាទ ខ្ញុំមិនចងចាំទេ ពីព្រោះសម័យនោះសូម្បីតែវិទ្យុស្តាប់ ខ្ញុំក៏គ្មានផង។ ហើយម្យ៉ាងទៀត ខ្ញុំក៏មិនបានដឹងថា អស់លោកធ្វើសមាជជាតិនៅកន្លែងណា ទីណានោះទេបាទ។

**ស៖** សូមអរគុណចំពោះការបញ្ជាក់របស់លោក ហើយខ្ញុំសូមបន្តទៅមុខទៀត។ ហើយខ្ញុំចង់ពិភាក្សាជាមួយលោកនូវឯកសារមួយទៀតដែលភ្ជាប់ទៅនឹងចម្លើយរបស់លោក គឺឯកសារ D200/9.12។ បាទនេះជាតារាងមួយដែលសាក្សីជាអ្នករៀបចំ ហើយតារាងនេះគឺត្រូវបានភ្ជាប់ទៅនឹងកំណត់ហេតុស្តាប់ចម្លើយសាក្សី ដែលបានធ្វើឡើងដោយការិយាល័យសហចៅក្រមស៊ើបអង្កេត។

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមការអនុញ្ញាតពីអង្គជំនុំជម្រះ បង្ហាញនូវតារាងនេះ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

**លោក អាប់ឌុលឡាក់ ចារីក៖**

ហើយខ្ញុំក៏សូមការអនុញ្ញាតឲ្យខាង អេ.វី យូនីត បង្ហាញនូវឯកសារនេះឲ្យបានយូរបន្តិច ដើម្បីឲ្យម្នាក់ៗគឺថាអាចយកមកធ្វើជាសំអាងនូវអ្វីដែលខាង -- ដែលយើងខ្ញុំនឹងធ្វើការតាំងជាសំណួរនោះ។

**សួរដោយលោក អាប់ឌុលឡាក់ ចារីក៖**

**ស៖** អ្វីដែលយើងឃើញនេះគឺជាអង្គការលេខ ដែលមានប្រអប់ជារាងចតុកោណកែងនៅខាងលើនេះចំនួនបួន។ ទី១ និយាយអំពី៨៧០, ក-១ ហើយបន្ទាប់គណ:៨៧០ ដែលមានសរសេរថា ប៉ុល ពត នៅក្នុងវង់ក្រចក ហើយប្រអប់រាងចតុកោណកែងមួយទៀត គណ:ប្រធានរដ្ឋ មានឈ្មោះ ខៀវ សំផន ហើយបន្ទាប់មកប្រអប់ខាងចុងបំផុត ខាងស្តាំ គឺសភាតំណាងប្រជាជន ដែលមានលោក នួន ជា ឈ្មោះ នួន ជា នៅខាងក្រោម។ លោកសាក្សី តើខ្ញុំអានឈ្មោះ ហើយនៅក្នុងប្រអប់រាងចតុកោណកែងទាំងបួននេះត្រឹមត្រូវដែរឬទេ?

[០៩:៣៨:០១]

**លោក នង សុផង់៖**

**ឆ៖** បាទ ត្រឹមត្រូវ។

**ស៖** នៅក្នុងអង្គការលេខខាងឆ្វេងនេះ ប្រអប់ទី១ នៅខាងក្រោម៨៧០ យើងមានប្រអប់តូចៗទៀតដែលដាក់ថា ទូរគមនាគមន៍ ដែលប្រអប់តូចបន្តទៅទៀតឈ្មោះ ប៉ុន, ផង់ និងឈ្មោះ យស់។ តើឈ្មោះ ផង់ នៅចំកណ្តាលគេនេះ ជាឈ្មោះដែលសំដៅទៅលើលោកមែនទេ?

**ឆ៖** បាទ គឺខ្ញុំ នង សុផង់ បាទ។

**ស៖** សូមអរគុណ។ នៅពេលដែលយើងឃើញព្រួញ ដែលបង្ហាញនៅផ្នែកខាងឆ្វេង ចង្អុលមកខាងក្រោមនេះ គឺសំដៅទៅលើភូមិភាគ និងតំបន់ស្វយ័ត។ ហើយក៏មានការ -- ព្រួញចង្អុលបង្ហាញត្រឡប់ទៅវិញពីភូមិភាគ ក៏ដូចតំបន់ស្វយ័តទាំងនេះទៅដល់ផ្នែកខាងទូរគមនាគមន៍ដែរ។ នេះគឺជាការរៀបរាប់ប្រព័ន្ធទំនាក់ទំនង ដែលគេបានធ្វើឡើងនៅក្នុងឆ្នាំ១៩៧៥ ដល់៧៩ នោះមែនទេ?

[០៩:៣៩:៣៤]

**ឆ៖** បាទ ពិតមែន គឺជាការទាក់ទងគ្នាតាមសារទូរលេខពីលើចុះក្រោម ហើយពីក្រោមឡើង

ទៅវិញ បាទ។ ហើយក៏សូមបញ្ជាក់បន្ថែមទៀតដែរ គឺតាមខ្ញុំចងចាំ គឺថាកាលនោះគឺវាមិនទាន់អស់ទេ ភូមិភាគគឺត្រូវបន្ថែម៨០១ មួយទៀតបាទ។ ហើយក៏មានបណ្តាញទាក់ទងថ្មីៗផ្សេងទៀតដែរនៅចុងឆ្នាំ ៧៨ ដែលខ្ញុំបាននឹកឃើញឡើងវិញបាទ គឺថាមានកងទ័ពជើងទឹកមួយក៏ឡើងមកត្រង់ដែរ ហើយទន្ទឹមនឹងនេះគឺមានខាងកំពង់ផែកំពង់សោម ខាងនេសាទសមុទ្រ ហើយនិងមានក្រុមមួយទៀតនៅប្រចាំការនៅអារញ្ញបាទ ដែលជាអង្គភាពទំនាក់ទំនងមកត្រង់មកខាងលើ ខាងមជ្ឈិមណេះបាទ។ នេះកាលដែលខ្ញុំបានរំឭក ឡើងវិញដែលពិនិត្យឡើងវិញទៅឃើញថាមានមិនទាន់អស់ទេបាទ ការទំនាក់ទំនងមានច្រើនក្រោយឆ្នាំ៧៨ហ្នឹង។

**ស៖** សូមអរគុណចំពោះការរៀបរាប់ល្អិតល្អន់របស់លោកនូវរចនាសម្ព័ន្ធទាំងនេះ។ ឥឡូវយើងនៅពិនិត្យទៅលើប្រអប់ផ្នែកខាងឆ្វេងដដែលនៃអង្គការលេខនេះដដែល។ យើងឃើញប្រអប់ចតុកោណកែងនៅខាងក្រោមផ្នែកខាងឆ្វេងនោះ ពីខាងលើទៅក្រោម គឺយើងមានតំបន់, ស្រុក, ឃុំ និងភូមិ ហើយបន្ទាប់មក យើងឃើញព្រួញគឺថា ចង្អុលបង្ហាញទៅវិញទៅមក ដែលត្រូវរាយការណ៍ទៅភូមិភាគិ ហើយពីភូមិភាគទៅខាងទូរគមនាគមន៍។ តើចំណុចនេះលោកចង់រៀបរាប់ថាយ៉ាងម៉េចដែរក្នុងអង្គការលេខនេះ?

[០៩:៤២:០១]

**ឆ៖** បាទ ខ្ញុំចង់បង្ហាញអំពីការទំនាក់ទំនង ចង់បង្ហាញថាខាងតំបន់, ខាងស្រុក, ភូមិ, ឃុំអីហ្នឹងគេចង់ទំនាក់ទំនងមកលើមិនបានឡើងមកផ្ទាល់មកខាងទូរគមនាគមន៍នោះទេ គេត្រូវឡើងទៅភូមិភាគសិន បានសេចក្តីរាយការណ៍ផ្សេងៗពីស្រុកផ្សេងៗ តំបន់ផ្សេងៗហ្នឹង។ ខាងភូមិភាគគេជាអ្នករៀបចំធ្វើរបាយការណ៍មកខាងលើនេះបាទ មិនអាចស្រុក, តំបន់, ភូមិ, ឃុំអីឡើងមកត្រង់មកខាងលើបានទេបាទ។ ចង់បញ្ជាក់ថាអ៊ីចឹង។ ហើយនេះគ្រាន់តែជាឧទាហរណ៍នៃភូមិភាគមួយ ឯភូមិភាគផ្សេងៗក៏គេរៀបចំដូចគ្នាអ៊ីចឹង អ្នកណាក៏គ្មានសិទ្ធិឡើងត្រង់មកទេ លើកលែងតែតំបន់ស្វយ័ត ដូចខ្ញុំបានបញ្ជាក់ គឺថាតំបន់បី មាន សៀមរាប, ឧត្តរមានជ័យ, ព្រះវិហារ និងមណ្ឌលគិរីបាទ ដែលគេមានសិទ្ធិឡើងត្រង់មកខាងទូរគមនាគមន៍បាទ។

**ស៖** ប្រហែលជាមានបញ្ហាបកប្រែល្អៀងបន្តិចបន្តួច គឺតំបន់បីដែលលោកបានរៀបរាប់គឺមានតំបន់ស្វយ័ត មានន័យថាជាភូមិភាគស្វយ័ត ឬក៏យ៉ាងម៉េចលោក តំបន់ស្វយ័តនេះ?

[០៩:៤៤:០៤]

**ឆ៖** បាទ តំបន់ស្វយ័ត គឺជាតំបន់មួយដែលឯករាជ្យ ដែលមិនស្ថិតនៅក្រោមឱវាទរបស់គណៈភូមិភាគទេ។ គឺគេមានបញ្ហាអី គេអាចធ្វើការទំនាក់ទំនងត្រង់មកមជ្ឈិមបក្សតែម្តង។ នេះគឺជាការទាក់ទង របស់តំបន់ស្វយ័ត គឺគេមានសិទ្ធិអ៊ីចឹង។

**ស៖** សូមអរគុណចំពោះការបំភ្លឺនេះ។ ឥឡូវ ខ្ញុំសូមចូលមកពិនិត្យមើលផ្នែកខាងឆ្វេងនៃអង្គការលេខ អ៎! សូមមកខាងស្តាំខាងទូរគមនាគមន៍នេះម្តង គឺនិយាយអំពី ស-៧១ ដែលក្នុងនុំង មានឈ្មោះ ប៉ង់, ភុំ និង កែន។ ហើយនៅក្នុងចម្លើយរបស់លោក ក្នុងឯកសារ E3/63, ERN ជាភាសាខ្មែរ 00294538, ជាភាសាបារាំង 00374935, ហើយជាភាសាអង់គ្លេស 00483966។ លោកបានរៀបរាប់ថា "នៅក្រោមការណែនាំរបស់គណៈ៨៧០ គឺមាន ស-២១ ដែលជាអង្គភាពមួយ ដែលមានឈ្មោះ ប៉ង់ ប្រធាន, ភុំ ជាអនុ និង កែន ជាសមាជិក ទទួលផ្នែកខាងសន្តិសុខនៅ ក-១។ ជុំវិញស-៧១ នោះយើងមាន ក-៧, ក-៨, ក-១៨ ហើយក្នុងបណ្តាញការងារនេះ គឺថាមានការណែនាំមកដល់ ប៉ង់ ពីរយៈតាមរយៈគណមជ្ឈិម។ ប៉ុល ពត គឺជាលេខាបក្ស និងប្រធានគណៈ៨៧០។ មិនមានអ្នកណាប្រើពាក្យថា ប្រធាន៨៧០ ទេ។ តាមធម្មតាសារទូរលេខគឺបង្ហាញជូនថា គណៈ៨៧០ មានន័យថា គណៈមជ្ឈិម"។ តើនេះ គឺអ្វីដែលខ្ញុំរៀបរាប់សង្ខេបត្រឹមត្រូវ តាមចម្លើយដែលលោកបានឆ្លើយជូនអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតមែនទេ?

[០៩:៤៧:០២]

**ឆ៖** បាទ សូមជម្រាបថា មិនមែន ស-២១ ទេ គឺ ស-៧១ បាទ ដែលជាអង្គភាពមួយស្ថិតនៅក្រោយឱវាទរបស់គណៈ៨៧០ បាទ។ ហើយដែលខ្ញុំរៀបរាប់អំពីមន្ទីរនានា ដែលនៅស្ថិតក្រោមឱវាទរបស់ស-៧១ ហើយនិងគណៈស-៧១ ហ្នឹង គឺជាការត្រឹមត្រូវបាទ ដែលលោកបាននិយាយអម្បាញ់មិញជាការត្រឹមត្រូវហើយ។

**ស៖** សូមអរគុណលោកសាក្សី ប្រហែលជាមកបញ្ហាបកប្រែ ឬក៏ខ្ញុំនិយាយទៅមិនត្រូវ ដែលនិយាយ -- តាមការពិត គឺនិយាយអំពី ស-៧១ មិនមែន ស-២១ ទេ។ ឥឡូវនេះ ខ្ញុំសូមរំឭកឡើងវិញគឺថា ស-៧១នេះ គឺជាអង្គភាពមួយដឹកនាំដោយ ប៉ង់ នៅក្រោម -- ដែលស្ថិតនៅក្រោមគណៈ៨៧០ តើវាត្រឹមត្រូវតាមអង្គការលេខដែលលោកគូរ អ៊ីចឹងមែនទេ?

**ឆ៖** បាទ ត្រឹមត្រូវបាទ។

**ស៖** បាទ សូមអរគុណ។ បើសិនជាយើងមើលទៅលើប្រអប់ចតុកោណកែងខាងលើ យើង

មានគណៈ៨៧០ ហើយនៅខាងស្តាំគណៈ៨៧០ហ្នឹង មានគណៈប្រធានរដ្ឋ គឺមាន ខៀវ សំផន ឈ្មោះ ខៀវ សំផន ក្រោមហ្នឹង មានរៀបរាប់ក្រសួងមួយចំនួន។ ហើយបន្ទាប់មកខាងស្តាំទៀត យើងមានប្រអប់ចតុកោណកែងមួយទៀត គឺសភាតំណាងប្រជាជន មានឈ្មោះ នួន ជា នៅខាងក្រោម។ ហើយខ្ញុំសូមអាននូវពាក្យពេចន៍ទាំងអស់នៅក្នុងតារាងនេះ ហើយបើសិនណាមិនត្រឹមត្រូវ សូមឱ្យលោកកែតម្រូវ។

[០៩:៤៩:២៩]

គឺបន្តពីឯកសារ E3/67 ដែលលោកនិយាយថា "នៅក្រោមការដឹកនាំរបស់គណៈមជ្ឈិមមានក្រសួងមួយចំនួន ហើយក្រសួងទាំងអស់នេះ គឺស្ថិតនៅក្រោមគណៈប្រធានរដ្ឋ ដែលមានលោក ខៀវ សំផន ជាប្រធានគណៈប្រធានរដ្ឋ។ ហើយនៅក្រោមការដឹកនាំរបស់បក្ស ក៏ដូចជារដ្ឋ នៅពេលនោះ គឺយើងមានក្រសួងព័ត៌មាន និងឃោសនាការ"។ ដោយសារតែពេលវេលា ខ្ញុំរៀបរាប់តែប៉ុណ្ណេះបានហើយ ហើយសម្រាប់ក្រសួងការពារជាតិ វាជាផ្នែកមួយនៃគណៈមជ្ឈិម ហើយក្រសួងនេះគឺត្រូវដឹកនាំដោយលោក សុន សេន ហើយខាងក្រោមមកទៀត ហើយបក្សក៏ដូចជារដ្ឋ ត្រូវជួបគ្នាដែលស្ថិតនៅក្រោមការដឹកនាំរបស់បក្ស។ រហូតមកដល់ពេលនេះ តាមសំណេរដែលនិយាយអំពីតារាងអង្គការលេខសរសេរដោយដៃលោកនេះ ថាតើវាត្រឹមត្រូវអីចឹងទេ ឬយ៉ាងម៉េចដែរ?

[០៩:៥០:៤៩]

**ឆះ** បាទ ខ្ញុំបានសរសេរដោយដៃផ្ទាល់ខ្ញុំមែន ប៉ុន្តែវាមានខុសខ្លះកន្លែងដែលខ្ញុំដាក់ដូចជាក្រសួងនានា គឺក្រសួងសេដ្ឋកិច្ច ហិរញ្ញវត្ថុគឺ វន វ៉េត។ អាកន្លែងហ្នឹង ខ្ញុំបានកែតម្រូវហើយ សូមកែតម្រូវថាឧស្សាហកម្ម និងរទេះភ្លើងគឺ វន វ៉េត បាទ ដែលខ្ញុំបានពិនិត្យចុះឡើង គឺខ្ញុំខុសកន្លែងហ្នឹងមែន ជា -- លោក វន វ៉េត មិនទទួលសេដ្ឋកិច្ចហិរញ្ញវត្ថុទេ គឺលោកទទួលឧស្សាហកម្ម និងរទេះភ្លើងបាទ។ នេះជាការពន្យល់ខុសរបស់ខ្ញុំ។ ហើយចំពោះក្រសួងការពារជាតិ គឺឯកឧត្តម សុន សេន ជាអគ្គមេបញ្ជាការ ហើយនៅក្រោមរបស់លោក គឺមានកងពលជាច្រើន ដែលស្ថិតនៅក្រោមឱវាទទាំងជើងទឹក ជើងគោក ជើងអាកាសហ្នឹង។ ហើយទាំងអស់ហ្នឹងមិនមានសិទ្ធិទាក់ទងមកខាង ត្រង់មកខាងទូរគមនាគមន៍ខ្ញុំទេ បាទ ន័យចង់បញ្ជាក់អីចឹង លើគំនូសហ្នឹង។ ហើយដែលខ្ញុំបាទបញ្ជាក់មួយអំមិញ គឺថាមានតែកងទ័ពជើងទឹកមួយទេ ដែលដឹកនាំដោយលោក មុត គឺមានប្រព័ន្ធទាក់ទងជាមួយខាងទូរគមនាគមន៍។ នេះចង់បន្ថែមលើបញ្ហាហ្នឹង ដើម្បីឱ្យកាន់តែយល់បាទពីគំនូសដែលខ្ញុំគូសនេះ។

[០៩:៥២:៣៤]

**ស៖** បាទ សូមអរគុណយ៉ាងច្រើនចំពោះការពន្យល់ល្អិតល្អន់របស់លោក។ ដូច្នេះយើងខ្ញុំបានយល់ពេញលេញហើយ។ ឥឡូវចូលទៅដល់ផ្នែកដែលខ្ញុំទើបនឹងអានអម្បាញ់មិញនេះ គឺមានសារ គឺមានអក្សរដែលសរសេរបន្តពីខាងដើមមក គឺគណៈប្រធានរដ្ឋ គឺនៅក្នុងរង្វង់ក្រចក យើងដាក់ថា "ឥឡូវនេះហៅថា រដ្ឋាភិបាល" ហើយក្នុងនោះគឺយើងមាន -- ក្នុងនោះក៏សភាតំណាងប្រជាជន។ សភាតំណាងប្រជាជន គឺមានលោក នួន ជា ជាប្រធាន។ នៅក្នុងរង្វង់ក្រចក គឺគេហៅថា "សភាតំណាងប្រជាជន"។ នៅពេលនោះ បក្សគឺថាទាំងអស់នេះ គឺស្ថិតនៅក្រោមបក្ស សូម្បីតែសភាតំណាងប្រជាជន ក៏នៅក្រោមបក្ស។ បក្សគឺគណៈ៨៧០ នេះឯង។ ហើយឃ្លាចុងក្រោយគឺខាងក្រោមនោះ "គណៈ៨៧០ គឺសំដៅទៅលើគណៈមជ្ឈិម សំដៅទៅលើ ប៉ុល ពត, នួន ជា, អៀង សារី និងមេដឹកនាំជាន់ខ្ពស់ដទៃទៀត។ ហើយ ស-៧១ គឺជាអង្គភាពមួយដែលជាផ្នែកមួយរបស់គណៈ៨៧០ ដែលក្នុងនោះយើងមានក្រសួងមួយចំនួនទៀត ហើយមិនមានៗសិទ្ធិគ្របដណ្ដប់ទៅលើក្រសួងការពារជាតិទេ"។ ថាតើនេះជាការរៀបរាប់របស់លោកទាក់ទងទៅនឹងអង្គការលេខនេះមែនទេ?

[០៩:៥៤:១៦]

**ឆ៖** បាទ ខ្ញុំបានរៀបរាប់អ៊ីចឹងមែនជូនចៅក្រមស៊ើបអង្កេតបាទ។

**ស៖** ហើយតាមការរៀបរាប់ទាំងនេះ តាមបទពិសោធន៍របស់លោក ក៏ដូចជាការយល់ដឹងរបស់លោក ដែលលោកធ្វើការនៅក្នុងអំឡុងនៃកម្ពុជាប្រជាធិបតេយ្យ គឺជាអ្វីដែលលោកបានរៀនសូត្រជាច្រើនពីអង្គភាពរបស់លោកនោះ ក្នុងការទាក់ទងទៅនឹងទំនាក់ទំនងជាមួយអ្នកដទៃទៀតនៅជុំវិញខ្លួនលោក។ តើលោកយល់ថាម៉េចដែរ?

**ឆ៖** បាទ តាមបទពិសោធន៍ក្នុងការរស់នៅ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យគឺថា អ្វីៗទាំងអស់ គឺបក្សគឺវាធំជាងអីទាំងអស់បាទ គឺមានអំណាចខ្ពស់ជាងគេ សូម្បីតែគណៈប្រធានរដ្ឋ សភាតំណាងប្រជាជន ទាំងអស់ហ្នឹងក៏ដែលជាស្ថាប័នធំៗនៅខាង -- នៅក្នុងរបបគ្រប់គ្រងកម្ពុជាប្រជាធិបតេយ្យពេលហ្នឹងគឺ ក៏នៅក្រោមឥទ្ធពល នៅក្រោមការគ្រប់គ្រង អំណាចគ្រប់គ្រងរបស់គណៈ៨៧០ ដែរបាទ។ នេះ គឺតាមដែលខ្ញុំធ្លាប់ដឹង ធ្លាប់ឮ គឺធ្លាប់បានទទួលនៅក្នុងសម័យហ្នឹង គឺការយល់ដឹងរបស់ខ្ញុំគឺៗថា អត់មាននរណាធំជាងបក្សទេ។ អត់អ្នកណាធំជាងគណៈ៨៧០ ទី១ គឺថា បងទី១ ហ្នឹងតែម្ដងដែលជាអ្នកធំជាង។ គឺ ប៉ុល ពត ហ្នឹងតែម្ដងបាទ។

[០៩:៥៦:៤២]

**ស៖** បាទ សូមអរគុណ។ ខ្ញុំសូមបញ្ចប់ការពិភាក្សាទៅលើអង្គការលេខនេះត្រឹមនេះទៅចុះ។ ខ្ញុំសូមសួរលោកបន្តអំពីកំណត់ហេតុដែលត្រូវរក្សាទុកនៅអង្គភាពរបស់លោក លោកបានពន្យល់នៅក្នុងការផ្តល់សក្ខីកម្មថា សម្រាប់សារទូរលេខដែលលោកត្រូវដាក់លេខកូដ គឺថាលោកបានរក្សាទុកការថតចម្លងមួយច្បាប់នៅអង្គភាពរបស់លោក តើលោកអាចជម្រាបជូនអង្គជំនុំជម្រះបានទេ ថាតើវាមានអ្វីកើតឡើងទៅដល់ឯកសារនៅក្នុងអង្គភាពរបស់ហ្នឹងនៅដើមខែមករា ៧៩នោះ?

**ឆ៖** បាទ ចំពោះអង្គភាពខ្ញុំ គឺនៅដើមខែមករា ៧៩ មុននឹងចេញមកគឺខ្ញុំមិនបានរក្សាទុក សូម្បីតែឯកសារសម្ងាត់មួយសន្លឹកក៏គ្មាននៅក្នុងហោប៉ៅខ្ញុំដែរ គឺខ្ញុំដុតចោលខ្ទេចអស់ហើយ។ អ៊ីចឹងអ្វីដែលអស់លោកយកបានការសម្ងាត់ទាំងអស់នេះ គឺពុំមែនជាអ្វីដែលខ្ញុំ និងអង្គភាពខ្ញុំត្រូវទទួលខុសត្រូវទេបាទ។

[០៩:៥៨:២២]

**ស៖** សូមអរគុណ។ តើលោក និងបុគ្គលិករបស់លោកជាអ្នកដុតឯកសារទាំងអស់ហ្នឹងចោល តើមានការណែនាំពីណា? អ្នកណាម្នាក់ជាក់លាក់ឲ្យដុតឯកសារទាំងអស់នោះចោលដែរឬទេ?

**ឆ៖** បាទ ពីព្រោះខ្ញុំចេញក្រោយគេ នៅថ្ងៃ៩ -- អំនៅថ្ងៃ០៧ មករា ឆ្នាំ៧៥ -- អំ នៅ ០៧ មករា ឆ្នាំ៧៩ គឺទាល់តែម៉ោងប្រាំបួនកន្លះព្រឹកហើយបានខ្ញុំចេញ។ គឺ អ៊ីចឹងគឺខ្ញុំយល់ឃើញថា ដែលត្រូវចេញហើយមិនអាចត្រឡប់មកវិញបានទេ អ៊ីចឹងគឺខ្ញុំត្រូវសម្រេចចិត្តដោយខ្លួនឯងតែម្តង។

**ស៖** សូមអរគុណលោក។ បាទ ប្រធានបទមួយចុងក្រោយគឺប្រហែលជា ខ្ញុំត្រូវការសាកសួរលោកតែ ២-៣នាទីទេ។ យើងបានពិភាក្សាយ៉ាងវែងឆ្ងាយអំពីតួនាទីរបស់ ប៉ុន ហើយនិង យស់ នៅក្នុងរថនាសម្ព័ន្ធទូរគមនាគមន៍។ លោកអាចជម្រាបជូនអង្គជំនុំជម្រះបានទេថា តើមានអ្វីកើតឡើងចំពោះអ្នកទាំងពីរនេះ? តើពួកគេទាំងពីរនេះបន្តធ្វើការងារនៅអង្គភាពនោះរហូតដល់ពេលវៀតណាមចូលមក ឬក៏យ៉ាងម៉េចដែរ?

**ឆ៖** បាទ អ្នកទាំងពីរនេះ ខ្ញុំមិនដឹងថា លោកបាននៅរហូតឬមួយក៏អត់។ ហើយខ្ញុំក៏មិនដឹងថាលោកបាត់ខ្លួនពីពេលណាដែរ។ បាទ នេះរឿងនេះខ្ញុំមិនអាចដឹងបានបាទ។

**ស៖** ខ្ញុំចង់បង្ហាញជូនលោកនូវឯកសារមួយទៀត ដើម្បីថាតើលោកចងចាំនូវឈ្មោះដែលមាននៅក្នុងឯកសារនេះទេ? ឯកសារនេះគឺឯកសារ IS16.90 នេះក៏ជាតារាងអង្គការលេខ ដែលនិយាយអំពី

ក្រសួង និង ស-៧១។

**លោក អាប់ឌុលឡាក់ ថារីក៖**

បាទ សូមការអនុញ្ញាតពីលោកប្រធាន ដើម្បីជូនឯកសារទៅសាក្សី និងបញ្ចាំងនៅលើអេក្រង់។

[១០:០១:២១]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

មន្ត្រីរដ្ឋបាលតុលាការ ទទួលឯកសារពីតំណាងសហព្រះរាជអាជ្ញាយកជូនសាក្សីពិនិត្យ!

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** លោក សុផង់ សូមលោកមើលទៅលើលេខ៨ នៅក្នុងបញ្ជីនេះ គឺមានឈ្មោះថា រស់ ផន ហៅ យស់ ហើយបន្ទាប់មកទៀត គឺ៨៧០ ហើយប្រហែលជាមានថា ហើយមានមន្ទីរ ប្រធានមន្ទីរ ក-១៨ ហើយនៅខាងស្ដាំបំផុត គឺមានកាលបរិច្ឆេទ ចុះថ្ងៃ១១ ខែ៥ ឆ្នាំ៧៥ ហើយនៅខាងស្ដាំគឺមានដាក់ថា ឯកសារ។ ថាតើឈ្មោះ យស់ ហ្នឹង គឺ យស់ ដែលលោកបានរៀបរាប់នៅក្នុងសក្ខីកម្មរបស់លោក នៅក្នុងឯកសាររបស់លោកដែរឬទេ?

**លោក នង សុផង់៖**

**ផ៖** បាទ ខ្ញុំស្គាល់តែឈ្មោះ យស់ តែឈ្មោះដើមរបស់លោកយ៉ាងណា ខ្ញុំមិនបានដឹង។ ប៉ុន្តែឃើញនៅក្នុងឯកសារដាក់ថា មន្ទីរ ក-១៨។ ក-១៨ គឺជាក្រុមខ័ណ្ឌរបស់លោក អង្គភាព មន្ទីររបស់លោកមែនបាទ។

**ស៖** សូមអរគុណ។ ហើយមានឈ្មោះមួយទៀតនៅក្នុងឯកសារដដែល គឺលេខ ១៨ គឺមានឈ្មោះ អ៊ុច ផន ហៅ ផុន អាយុ៣០ឆ្នាំ ជាប្រធានមន្ទីរទូរស័ព្ទ គឺថាខែ -- គឺថ្ងៃ៤ មេសា ឆ្នាំ៧៨ ហើយបន្ទាប់មកទៀតមានឈ្មោះថា សាក សួរ។ ថាតើនេះគឺជាឈ្មោះ ប៉ុន ដែលយើងបានពិភាក្សាប៉ុន្មានថ្ងៃកន្លងមកនេះ តើមែនទេ?

[១០:០៣:៥២]

**ផ៖** បាទ ខ្ញុំមិនស្គាល់ឈ្មោះដើមរបស់ ប៉ុន ទេ។ តែបើពិនិត្យពីអាយុ ហើយនិងភេទ ហើយក៏គាត់ជាប្រធានមន្ទីរទូរស័ព្ទរបស់ក្រសួង អានេះគឺមិនមែនតែទូរស័ព្ទទេ គឺគាត់ទទួលទូរស័ព្ទនៅក្រុងភ្នំពេញទាំងអស់ផង ហើយនិងគ្រួតពីលើខ្ញុំហ្នឹងផងបាទ។ អ៊ីចឹងប្រហែល ១ជាហ្នឹងមែនក៏មិនដឹង។

អានេះ ខ្ញុំមិនច្បាស់ទេ ពីព្រោះថា មិនបានឃើញរូបរបស់គាត់ផ្ទាល់។ ហើយក្រសួង -- កន្លែងដែលគេដាក់ថា មន្ទីរទូរស័ព្ទរបស់ក្រសួងនេះ ក៏មិនទាន់ច្បាស់ទេ។ បើថា អ្នកកាន់ទូរលេខសម្ងាត់របស់ ប៉ុល ពត របស់មជ្ឈិមអ៊ីចឹងបានវាច្បាស់បាទ។ នេះគឺមានការដាក់ចំណារ អំពីតួនាទីរបស់គាត់ហ្នឹងវាមិនច្បាស់លាស់បាទ។

[១០:០៥:១០]

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោក សុផង់។ ខ្ញុំមិនមានសំណួរបន្ថែមទៀត ដើម្បីសាកសួរលោកឡើយ ហើយខ្ញុំសូមថ្លែងអំណរគុណ ចំពោះលោក តាងនាមឲ្យការិយាល័យសហព្រះរាជអាជ្ញា ដែលលោកបានផ្តល់មក -- ដែលលោកបានអញ្ជើញមកផ្តល់សក្ខីកម្ម និងបានផ្តល់នូវភស្តុតាងដ៏លម្អិត។

លោកប្រធានតាមការកំណត់ពេលវេលា ហើយប្រសិនបើលោកប្រធានអនុញ្ញាត ខ្ញុំសូមទុកឱកាសបន្តទៅភាគីមួយទៀត។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អរគុណ។

អង្គជំនុំជម្រះ សូមផ្តល់វេទិកាជូនទៅសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីមានឱកាសក្នុងការតាំងសំណួរដេញដោល ចំពោះសាក្សីរូបនេះ។

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម។ មេធាវីដែលទទួលសិទ្ធិក្នុងនាមមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី គឺលោកស្រីមេធាវី ទី ស្រ៊ីនណា និងកញ្ញាមេធាវី ហ្វីលីពីន ស៊ុតហ្ស៍។ សូមអរគុណលោកប្រធាន សូមអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត សូមអញ្ជើញ!

**លោកស្រី ទី ស្រ៊ីនណា៖**

ជាបឋម នាងខ្ញុំសូមគោរព លោកប្រធាន លោក លោកស្រីចៅក្រម និងអង្គសវនាការទាំងមូល។

[១០:០៦:២៨]

**ការតាំងសំណួរដោយសហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី**

**សួរដោយលោកស្រី ទី ស្រ៊ីនណា៖**

**ស៖** នាងខ្ញុំ ឈ្មោះ ទី ស្រ៊ីនណា ជាមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ហើយក៏សូមធ្វើការគោរពដល់លោក នង សុផង់ ហើយនិងសូមធ្វើការថ្លែងអំណរគុណ ចំពោះការអំណត់របស់លោកដែលបានមកធ្វើការឆ្លើយនៅចំពោះមុខសាលសវនាការនេះ តាំងពីថ្ងៃ២៩ រហូតមកដល់ថ្ងៃនេះ។ សំណួររបស់ខ្ញុំនឹង -- ខ្ញុំនឹងសូមធ្វើការតាំងសំណួរមួយចំនួនទៅលោក ដើម្បីធ្វើការបញ្ជាក់បន្ថែម ហើយខ្ញុំសូមធ្វើការសួរបកត្រឡប់ទៅខាងដើមបន្តិច ទាក់ទងទៅនឹងចម្លើយរបស់លោកដែលបានឆ្លើយ កាលពីថ្ងៃ២៩ សីហា ឆ្នាំ២០១២ ដែលទាក់ទងទៅនឹងស្ថានភាពមុនឆ្នាំ១៩៧៥។ នៅក្នុងនោះលោកក៏បានឆ្លើយជាមួយនឹងសហព្រះរាជអាជ្ញាដែរថា លោកធ្លាប់បានជួបជាមួយនឹង ប៉ុល ពត ក៏ដូចជាលោក នួន ជា នៅ ប-១៧។ តើ -- សំណួររបស់ខ្ញុំចង់សួរបញ្ជាក់បន្ថែមថា ពេលនុ៎ងលោកបានជួបជាមួយនឹងលោក នួន ជា ក៏ដូចជា ប៉ុល ពត ហ្នឹងចំនួនប៉ុន្មានដងដែរ?

**លោក នង សុផង់៖**

**ឆ៖** បាទ នៅប-១៧ ខ្ញុំមិនបានជួបដោយផ្ទាល់ ធ្វើការសំណេះសំណាលអ្វីទេ គឺគ្រាន់តែថា ឃើញ បានឃើញ លោក ប៉ុល ពត និង នួន ជា ដែលលោកថា ដើរមួយគ្រួសអ៊ីចឹងទៅពិនិត្យការងារដែលក្រុមខ្ញុំបង្កបង្កើនផលនោះ។ ហើយខ្ញុំពេលដែលលោកដើរមួយគ្រួសហ្នឹង ក៏ខ្ញុំមិនស្គាល់ថា លោកណាទេ ពីព្រោះខ្ញុំជាអ្នកមកលត់ដំថ្មី។ ពេលដែលលោកអញ្ជើញត្រឡប់ទៅវិញ បានខ្ញុំហ៊ានសួរគេ ថាតើបងៗមាឌធំៗហ្នឹងឈ្មោះបងអីបាទ នេះបានគឺអ៊ីចឹងទេបាទ មិនមានការជួបពិភាក្សាសំណេះសំណាលអ្វីទេបាទ។

[១០:០៩:០៣]

**ស៖** សូមអរគុណ។ ដោយសារលោកបានបញ្ជាក់ហើយៗ អ៊ីចឹង ខ្ញុំសូមធ្វើការបន្តសំណួរទៅនៅក្នុងប-១៧ហ្នឹងដដែល។ ថាតើប-១៧ហ្នឹងគឺជា -- លោកបានមានប្រសាសន៍ថា ប-១៧ ជាកន្លែងលត់ដំ តើប-១៧ ហ្នឹង គេលត់ដំទៅលើផ្នែកណាខ្លះដែរ?

**ឆ៖** បាទ ប-១៧ ជាកន្លែងលត់ដំគោលជំហរ ដូចខ្ញុំបានជម្រាបលោកខាងដើមហ្នឹង លោកស្រីបានដឹងហើយគឺថា ក្នុងសម័យហ្នឹង ក្នុងការជ្រើសរើសមនុស្សដើម្បីឱ្យមកធ្វើការងារអ្វីមួយ ព្រោះខ្ញុំកាលហ្នឹងក៏វាជាហៅថា ពិនិត្យពីសមាសភាពវណ្ណៈ គឺជាវណ្ណៈកណ្ដាល អនុធន បញ្ញាជនមួយដែរ។

អ៊ីចឹងគឺដើម្បីបំពេញការងារសំខាន់ៗរបស់បក្សទាល់តែយើងបានលត់ដំ គេដឹងថាយើងហ្នឹងស៊ូទ្រាំនឹងធម្មជាតិបាន មិនបាន។ ការបង្កបង្កើនផលហ្នឹងទាំងក្តៅ ទាំងថ្ងៃ ទាំងភ្លៀង យើងៗអាចតស៊ូបានដូចកសិករទេ បាទ--

**ស៖** សូមៗ--

**ឆ៖** អានេះគឺអ៊ីចឹង បាទ។

[១០:១០:៣៩]

**ស៖** សូមអត់ទោស ខ្ញុំចង់សូមសួរថា តើកន្លែងប-១៧ ហ្នឹង លោកថាជាកន្លែងលត់ដំបុគ្គល -- មនុស្សជាមុនសិន មុននឹងមកធ្វើការឲ្យបក្សកុម្មុយនីស្ត។ ខ្ញុំចង់សួរ ថាតើគេលត់ដំទៅលើផ្នែកអីគេខ្លះ? ដូចជាលោកនៅក្នុងផ្នែកបកប្រែអ៊ីចឹង លោកមានការលត់ដំទៅលើផ្នែកបកប្រែ ចុះមានការលត់ដំទៅលើផ្នែកអីផ្សេងៗទៀតដែរឬទេ?

**ឆ៖** បាទ មិនមែនលត់ដំលើផ្នែកបកប្រែហ្នឹងទេ ពីព្រោះមុននឹងយកមកបកប្រែ គេឲ្យលត់ដំខាងគោលជំហរ ដូចខ្ញុំបានបញ្ជាក់ខាងដើមហ្នឹង គឺថាអត់មានលត់ដំខាងបកប្រែទេបាទ។

**ស៖** សូមអរគុណ ខ្ញុំច្បាស់ហើយ។ ហើយឥឡូវខ្ញុំសូមទាញមកស្ថានភាពក្រោយឆ្នាំ១៩៧៥ វិញ។ ទាក់ទងទៅនឹងស្ថានភាពក្រោយឆ្នាំ៧៥ លោកថា លោកពេលដែលលោកមកដល់ភ្នំពេញហ្នឹង លោកថាលោកធ្លាប់ជាអ្នក ដែលទទួលការបកៗប្រែសារទូរលេខទៅលើជ័យជម្នះរបស់បក្សកុម្មុយនីស្ត។ ហើយសំណួររបស់ខ្ញុំមិនសួរលម្អិតទៅលើករណីហ្នឹងទេ ក៏ប៉ុន្តែចង់សួរ -- ឈ្លេចសួរបន្ថែម ថាតើលោកមានដែលប្រទះជួបសារទូរលេខ ដែលគេនិយាយអំពីការចាត់ចែងខ្មាំង លន់ នល់ បន្ទាប់ពីមានការវាយដណ្តើមបានទីក្រុងភ្នំពេញដែរឬទេ? បើមានតើសារទូរលេខនោះចេញដោយនរណា? ហើយគេកំណត់ខ្មាំង លន់ នល់ យ៉ាងដូចម្តេច?

[១០:១២:២៧]

**ឆ៖** បាទ ខ្ញុំមិនដែលធ្លាប់បកប្រែសារទូរលេខនិយាយអំពីលោក លន់ នល់ ទេបាទ។ ហើយខ្ញុំក៏មិនដឹង ពីព្រោះតាមដឹង គឺថាលោក លន់ នល់ គឺលោកបានរត់ទៅអីណាអីណីហ្នឹងមុនឆ្នាំចិតសិប -- មុនពេលរំដោះមកហើយ បាទ។ ដូច្នេះមិនមាននិយាយពីរឿងលោក លន់ នល់ អីទេបាទ។ ឯសារដែលគេធ្វើមកខ្ញុំ អំពីដំណឹងជ័យជម្នះនេះ សូមបញ្ជាក់ជូនលោកស្រីថា មិនមែនជាសារសម្ងាត់ទេ មិនមែនចាំបាច់បកប្រែទេ គឺចេញជាម៉ាស អក្សរម៉ាស ជាដំណឹងជ័យជម្នះតែម្តង អ៊ីចឹងតែម្តង ចេញជាអក្សរតែម្តង

មិនចាំបាច់បកប្រែតាមលេខកូដសម្ងាត់ទេ។

**ស៖** សូមបញ្ជាក់ជាមួយលោកម្តងទៀត ខ្ញុំ -- សំណួររបស់ខ្ញុំគឺអត់សំដៅទៅលើលោក លន់ នល់ ទេ ក៏ប៉ុន្តែសំណួររបស់ខ្ញុំគឺសំដៅទៅលើខ្មាំង លន់ នល់ ពីព្រោះនៅក្នុងបក្សកុម្មុយនីស្តកម្ពុជា យើងបានធ្វើប្រយុទ្ធប្រឆាំងគ្នាជាមួយនឹងខាង លន់ នល់ ដើម្បីវាយដណ្តើមយកភ្នំពេញ។ អ៊ីចឹងតើបន្ទាប់ពីវាយបានៗ ទីក្រុងភ្នំពេញហើយ តើនៅក្នុងជួរបក្សហ្នឹង គេមានធ្វើការកំណត់ទៅលើទាហាន លន់ នល់ ថាជាខ្មាំង ហើយខ្មាំងហ្នឹងគេមានធ្វើការចេញសារទូរលេខ ដើម្បីកំណត់ថាត្រូវចាត់ចែងយ៉ាងម៉េចចំពោះទាហាន លន់ នល់ ដែរឬទេ? លោកមានដែលប្រទះឃើញសារបែបហ្នឹង ហើយគេនិយាយពីខ្លឹមសារហ្នឹងដែរទេ? ហើយបើសិនជាករណីដែលលោកអត់ដែលប្រទះឃើញសារទូរលេខទេ តើលោកមានដែលដឹងឮអំពីបញ្ហានៅក្នុងការដែលគេចាត់ចែងទៅលើទាហាន លន់ នល់ ដែរឬទេ?

[១០:១៤:៣១]

**ធ៖** បាទ ខ្ញុំមិនដឹង ហើយក៏ខ្ញុំមិនធ្លាប់ឃើញដែរ ពីព្រោះខ្ញុំនៅ ដូចលោកស្រីដឹងហើយ ខ្ញុំបានជម្រាបជូនថា ខ្ញុំវានៅតែក្នុងព្រៃចេក បាទ។ ឯការជាក់ស្តែងយ៉ាងម៉េចៗ គឺខ្ញុំមិនបានដឹងសភាពនៅតាមមូលដ្ឋាននានានោះទេបាទ។ ហើយសារដែលៗខ្ញុំបកប្រែនៅពេលហ្នឹងក៏មិនដូចជាមិនឃើញនិយាយអំពីការកំណត់អំពីទាហាន លន់ នល់ យ៉ាងម៉េចអីយ៉ាងម៉េច គឺមិនដែលឃើញតែម្តងបាទ។

**ស៖** ខ្ញុំធ្វើការបញ្ជាក់បន្តទៀត ទាក់ទងទៅនឹង កាលពីសប្តាហ៍មុនលោកបានលើកឡើងថាសារបញ្ជូនចូលជារបាយការណ៍ និងសារបញ្ជូនចេញជាសេចក្តីណែនាំ។ ហើយកាលពីម្សិលមិញផងដែរ លោកក៏បានបំភ្លឺជាមួយនឹងខាងសហព្រះរាជអាជ្ញាដែរថា សារទូរលេខខ្លះជាប្រភេទសារខ្លីៗ ស្នើសុំមកពីគណៈតំបន់ទៅកាន់គណៈ៨៧០។ អ៊ីចឹងសំណួររបស់ខ្ញុំចង់សួរថា តើសារទូរលេខហ្នឹងមានប៉ុន្មានប្រភេទដែរ?

**ធ៖** បាទ សារទូរលេខដែលទាក់ទងចង់ជួបពីគណៈតំបន់មកខាងលើនេះ គឺជាសារទូរលេខសម្ងាត់បាទ ពីព្រោះទាក់ទងនឹងដំណើរជួបគ្នារវាងកម្មាភិបាលដឹកនាំជាមួយខាងលើអ៊ីចឹង គឺគេត្រូវធ្វើជាសម្ងាត់ហើយបាទ។ តែក្នុងសម័យហ្នឹងខ្ញុំក៏ហាក់ដូចជាមិនទាន់ -- មិនបានឃើញទូរលេខដែលខាងតំបន់ ឬខាងភូមិភាគណាមកស្នើសុំជួបដោយសម្ងាត់ដែរបាទ អត់ឃើញទេបាទ។

[១០:១៧:០១]

**ស៖** សូមអត់ទោសប្រហែលជាសំណួរខ្ញុំមានលក្ខណៈមិនច្បាស់លាស់។ អ៊ីចឹង ខ្ញុំសូមបញ្ជាក់

លោកម្តងទៀត ចង់ឲ្យលោកធ្វើការ -- តើនៅក្នុងពេលដែលលោកធ្វើការជាអ្នកបកប្រែហ្នឹង គេមានកំណត់អំពីប្រភេទសារទូរលេខដែរឬទេ? ថាតើប្រភេទសារទូរលេខហ្នឹងគេកំណត់យ៉ាងដូច -- ដូចថាមានកំណត់យ៉ាងម៉េចខ្លះ? ដូចជាមានសារស្នើសុំ ជាលក្ខណៈសារបញ្ជូនជាលក្ខណៈព័ត៌មាន ជារបាយ-ការណ៍ ឬក៏មានប្រភេទសារផ្សេងៗទៀតដែរឬទេ ឬក៏មានតែពីរប្រភេទហ្នឹង?

**ឆ៖** បាទ ប្រភេទនៃសារទូរលេខ វាមានសារទូរលេខចំហ និងសារទូរលេខសម្ងាត់។ បាទ មានតែពីរប្រភេទហ្នឹងទេ។ សារទូរលេខចំហគឺសំដៅថា ដំណឹងជ័យជម្នះផ្សេងៗ អាហ្នឹងគឺជាដំណឹងចំហ ដែលគេអាចផ្សាយទូទៅពេញពិភពលោក។ ឯប្រភេទសារសម្ងាត់ គឺជាប្រភេទសារដែលគេត្រូវបង្វែងដានពីរបីជាន់បាទ។ បាទ មានតែពីរប៉ុណ្ណឹងទេបាទ។

[១០:១៨:២២]

**សៈ** លោកបានលើកឡើងអំពីសារសម្ងាត់ អ៊ីចឹង ខ្ញុំចង់បន្តសំណួរថា តើសារដែលសម្ងាត់ហ្នឹងនរណាជាអ្នកកំណត់ថាសារហ្នឹងជាសម្ងាត់? ក្រុមរបស់លោកជាអ្នកកំណត់ដោយផ្ទាល់ ឬក៏ម្ចាស់សារជាអ្នកកំណត់?

**ឆ៖** បាទ រឿងនេះវាមិនជាពិបាកចំណាំ ពិបាកយល់ទេ ពីព្រោះវាមានគោលការណ៍នៅក្នុងក្រុមរបស់យើងខ្ញុំហ្នឹង។ គឺអ្នកណាក៏គេចេះពិនិត្យថា អ្វីជាសម្ងាត់ អ្វីជាចំហ បានដែរ។ នេះគឺជាគោលការណ៍មួយដែលគេបានបែងចែកច្បាស់លាស់នូវសារណាជាសារសម្ងាត់ សារណាជាសារចំហ។ ប៉ុន្តែបើចំពោះសារសម្ងាត់គឺមាន -- គេអាចដាក់ថា ចារដោយអ្នកដឹកនាំដែលសរសេរថា "សម្ងាត់ដាច់ខាត" អីអ៊ីចឹងក៏មានដែរបាទ។

**សៈ** សូមអរគុណចំពោះចម្លើយរបស់លោក។ ទាក់ទងទៅនឹងបទពិសោធន៍របស់លោក លោកថាលោកមានការ -- គាត់ -- លោកធ្វើការងារជាអ្នកបកប្រែសារទូរលេខ។ អ៊ីចឹងខ្ញុំចង់សួរថា នៅពេលដែលលោកបកប្រែសារទូរលេខហើយ ហើយសារទូរលេខនឹងត្រូវបញ្ជូនទៅមុខសញ្ញា ឬក៏មុខព្រួញដែលត្រូវបញ្ជូនទៅ។ អ៊ីចឹង ខ្ញុំចង់សួរថាតើបន្ទាប់ពីលោកធ្វើការបកប្រែហើយ មានការផ្ទៀង -- មានអ្នកផ្ទៀងផ្ទាត់ ឬក៏ត្រួតពិនិត្យពីលើសាររបស់លោកដែរឬទេ ថាតើសារហ្នឹង មានលក្ខណៈត្រឹមត្រូវតាមច្បាប់ដើម ឬក៏យ៉ាងម៉េច?

**ឆ៖** បាទ នៅក្នុងក្រុមខ្ញុំ មុននឹងយកសារហ្នឹងឡើងទៅខាង ក-១ គឺខ្ញុំហ្នឹងហើយជាអ្នកត្រួតពិនិត្យនូវអ្វីៗដែលប្អូនៗនៅក្នុងក្រុមរបស់ខ្ញុំ ជាអ្នកបកប្រែហ្នឹង។ អ៊ីចឹង គឺនៅក្នុងនេះ គឺខ្ញុំហ្នឹងហើយ

ជាអ្នកត្រួតពិនិត្យ ថាតើមាន តាំងពីអក្ខរាវិរុទ្ធឡើងទៅ មានខុស មានត្រូវអីទេ មុននឹងបញ្ជូនទៅបន្តទៀតបាទ។

[១០:២០:៥៤]

**ស៖** លោកថា លោកមានការត្រួតពិនិត្យ ថាអ្វីដែលសារដែលត្រូវធ្វើការបកប្រែ ហើយនិងមានការត្រួតពិនិត្យលោកហើយ តើសារទាំងអស់នោះ មានការទទួល -- ដូចថាខ្លឹមសារនៃសារហ្នឹង មានការទទួលស្គាល់ពីថ្នាក់លើ ឬក៏ម្ចាស់ថា មានលក្ខណៈត្រឹមត្រូវតាមទូរលេខដើមដែរឬទេ?

**ឆ៖** បាទ ចំពោះការខុសឆ្គង ឬក៏មួយកន្លែងណាដែលមិនច្បាស់លាស់ ក៏មានខាងលោក ប៉ុនហ្នឹង គាត់អាចសួរបញ្ជាក់ដើម្បីមកផ្ទៀងផ្ទាត់ ឬមួយក៏ឃ្លាប្រយោគមួយមិនច្បាស់ ឬមួយក៏ខុសអក្ខរាវិរុទ្ធ ដែលខាងខ្ញុំបញ្ជូនទៅហើយ ក៏គាត់អាចគូសពីក្រោម ហើយសួរបញ្ជាក់ខ្ញុំតាមទូរស័ព្ទបានដែរបាទ។

**ស៖** ទាក់ទងទៅនឹងសារទូរលេខមួយចំនួន ដែលខាងសហព្រះរាជអាជ្ញាគាត់បានធ្វើការបង្ហាញជូនលោក ដើម្បីបំភ្លឺជូនអង្គសវនាការ។ នៅក្នុងនុំង លោកបានឆ្លើយបំភ្លឺទាក់ទងទៅនឹងទម្រង់នៃសារទូរលេខ។ អ៊ីចឹង សំណួររបស់ខ្ញុំ ចង់សួរបញ្ជាក់បន្ថែមអំពីការដើរលេខរៀងនៃសារ។ នៅក្នុងនុំង តាមសង្កេតៗរបស់ខ្ញុំទៅលើលេខរៀងនៃការដើរលេខរៀងនៃសារទូរលេខ ឃើញមានពីលេខ១ រហូតមានលំដាប់លំដោយទៅហូរហែ។ តើអាហ្នឹង គេធ្វើការកំណត់យ៉ាងដូចម្ដេច? គេកំណត់ជាលក្ខណៈឆ្នាំ? ឬមួយក៏គេដើររហូតចាប់ពី៧៥ រហូតដល់៧៩ តែម្ដង ឬក៏យ៉ាងម៉េច?

**ឆ៖** បាទ បញ្ហានេះ វាជាគោលការណ៍រួម សារទូរលេខមិនសូវមានលេខដល់រាប់រយទេ។ គឺច្រើនតែពី០១ រហូតដល់ ៩៩ ហ្នឹងជាទូទៅតែម្ដង។ ក៏ប៉ុន្តែដូចអម្បាញ់មិញ ខ្ញុំបានឃើញសារទូរលេខខ្លះរហូតដល់ពីបីរយអ៊ីចឹង។ ប្រហែលជាការដាក់លេខរៀងរបស់ក្រុមបកប្រែនុំង គឺគាត់ បែបចាប់តាំងពីធ្វើសារ រហូតដល់គាត់ធ្វើថ្ងៃហ្នឹង គឺគាត់គិតតាំងពី ដែលគាត់ចេញសារទី១ រហូតដល់ប៉ុន្មានរយៗហ្នឹង។ អាហ្នឹងករណីភូមិភាគមួយ ឃើញធ្វើអ៊ីចឹង។ អ៊ីចឹង គឺ -- តែការកំណត់ទូទៅ នៅក្នុងក្រុមបកប្រែរបស់យើងខ្ញុំ គឺថាពេលណាដល់៩៩ ហើយ គេត្រូវត្រឡប់មក ០១ វិញហើយបាទ។

[១០:២៤:៣១]

**ស៖** ខ្ញុំសូមសួរថាតើការកំណត់ដែលមានលក្ខណៈពី ០១ ឡើងទៅ ហើយក៏ដូចជាការកំណត់ពីសារទូរលេខ -- អ៊ំ ពីលេខរៀង និយាយលេខរៀងនៃសារ។ លេខរៀងនៃសារហ្នឹង ពី០១ រហូតដល់៩៩

និងលោកបានលើកអម្បាញ់មិញថា មានសារទូរលេខខ្លះ មានដល់ទៅខ្ទង់២០០, ៣០០ ប្រហែល លោកគិតថា វាជាអ្នកដែលធ្វើក្រុមសារទូរលេខហ្នឹង គេនឹងធ្វើចាប់ពី៧៥ ដល់៧៩ តើអ៊ីចឹងមែនឬទេ? តើវាមានភាពខុសគ្នាយ៉ាងម៉េចដែរ?

**ឆ៖** បាទ--

**ស៖** ខ្ញុំសូមបន្តទៀត (សូមទោស) តើទម្រង់នៃការធ្វើបែបហ្នឹងលោកៗផ្ទាល់ដែលធ្លាប់មានបទពិសោធន៍ តើលោកអាចទទួលយកបានពីភាពខុសគ្នាហ្នឹងដែរឬទេ?

**ឆ៖** បាទ ទូរលេខដែលមានភាពខុសគ្នារវាងការដាក់លេខរៀងនេះ ខ្ញុំអាចទទួលយកបានថា វាអត់មានអ្វីដែលខុសពីទូរលេខដែលខាងយើងខ្ញុំបានបកប្រែទេ។ គ្រាន់តែថាអង្គភាពមួយនេះ ពិសេសគឺដែលមានស៊ីញ៉េថា សែ នេះ គឺគាត់មានដាក់ -- ការដាក់លេខរៀងនេះវាខុសគេបាទ គឺប្រហែលជាគាត់គិតតាំងពី ០១, ០២ រហូតដល់សាររបស់គាត់ហ្នឹងដែលចេញមកវាមានដល់ ៣២៤ ហើយបាទ។ នេះគឺមិនជាបញ្ហាអ្វីធំដុំទេ លើការលេខរៀងនេះបាទ។

[១០:២៦:៤៨]

**ស៖** អ៊ីចឹងខ្ញុំសូមធ្វើការបញ្ជាក់បន្ថែមទៅលើសារទូរលេខ ដែលខាងសហព្រះរាជអាជ្ញាគាត់បង្ហាញជូនលោកកាលពីម្សិលមិញ។ ម្សិលមិញសហព្រះរាជអាជ្ញាបានបង្ហាញសារទូរលេខមួយចំនួន ហើយនៅក្នុងនោះលោកក៏បានឆ្លើយបំភ្លឺ ដោយសារទូរលេខហ្នឹងមានតាំងពីចំណាររបស់បុគ្គលមួយចំនួនដែលលោកបានស្គាល់ទាំងអក្សរដៃរបស់បុគ្គលនោះទៀត។ អ៊ីចឹងខ្ញុំចង់សួរបញ្ជាក់ថា តើទម្រង់និងការប្រើប្រាស់សារទូរលេខបែបហ្នឹង គឺពិតជាមាននៅក្នុងរបប -- ពិតមានបានប្រើប្រាស់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យដែរមែនឬទេ?

**ឆ៖** បាទ ពិតមែនបាទ។ ព្រោះទម្រង់គឺមានក្បាល និងកន្ទុយ ប៉ុន្តែទម្រង់របស់កន្លែងនីមួយៗគេមិនដាក់ដូចគ្នានឹងកន្លែងមួយផ្សេងទៀតទេ។ ឧទាហរណ៍ថា ខ្លះគេដាក់ថា គោរពជូនគណៈ៨៧០ ខ្លះគេដាក់ជូនបងជាទីស្នេហា និងរឭក ខ្លះគេដាក់ ជូនអង្គការ៨៧០ ប៉ុន្តែឃើញថា ទម្រង់ហ្នឹងគឺវាមានជាក្បាលគឺត្រូវតែអ៊ីចឹង។ ជូនពីណា ទូរលេខ លេខប៉ុន្មានអីអ៊ីចឹង។ ហើយចុងបញ្ចប់នៃសារទូរលេខគឺវាត្រូវតែមានពាក្យពេចន៍ដែលថា ជូនពរ សុខសប្បាយ និងជ័យជម្នះ ឬមួយក៏ ដោយគោរព ដោយភាតរភាពបដិវត្តន៍យ៉ាងកក់ក្ដៅបំផុត អីអ៊ីចឹង គឺជាទម្រង់ដែលអ្នកសរសេរមួយៗទៅតាមភូមិភាគគេនិយម។ ប៉ុន្តែទោះបីយ៉ាងម៉េច គឺថាវាមានក្បាលអ៊ីចឹង មានកន្ទុយអ៊ីចឹង ហើយមានការចុះហត្ថលេខា

មានការចុះកាលបរិច្ឆេទ ដែលគេសរសេរសារ ហើយនិងចុះហត្ថលេខាអ្នកដែលធ្វើសារមកបាទ។ នេះគឺទម្រង់ហ្នឹង គឺទូរលេខណាក៏មានទម្រង់អ៊ីចឹងដែរ។

[១០:២៩:១២]

ឯចំពោះកណ្តាលវិញ ដូចខ្ញុំបានជម្រាបអង្គសវនាការហើយ គឺគេមិនសរសេរងាប់ក្រឡាទេ អត់មានទម្រង់អីច្បាស់លាស់ទេ ពីព្រោះការងារទំនាក់ទំនងខាងសារទូរលេខនេះ ជាគោលការណ៍គឺគេត្រូវឲ្យខ្លី តែឲ្យច្បាស់។ អ៊ីចឹងអ្នកណាមានសភាពការណ៍អីក៏គេដាក់ទៅតាមសភាពការណ៍ជាក់ស្តែងដែលកន្លែងមួយៗគេត្រូវចាំបាច់ឲ្យថ្នាក់លើដឹង។ អ៊ីចឹងឧទាហរណ៍ ខ១ គេនិយាយអី ខ២ និយាយពីអី ខ៣ និយាយពីអី។ អត់មានទម្រង់អីច្បាស់លាស់ទេ នៅកន្លែងកណ្តាលនេះបាទ។ បាទ សូមជម្រាបប៉ុណ្ណឹងបាទ។

**ស៖** អ៊ីចឹងមានន័យថា លោកទទួលស្គាល់ថា ពិតជាមានប្រើទម្រង់ហ្នឹងប្រាកដមែននៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ?

**ឆ៖** បាទ ពិតប្រាកដមែន។

**ស៖** សូមអរគុណ។ ទាក់ទងទៅនឹងការជម្លៀសប្រជាជនពីតំបន់មួយទៅតំបន់មួយ អ៊ីចឹងខ្ញុំចង់សួរពាក់ព័ន្ធទៅនឹងចំណុចហ្នឹងបន្តិច លោកបានឆ្លើយកាលពីម្សិល សហព្រះរាជអាជ្ញាបានបង្ហាញឯកសារលេខ E3/1679D ជាប្រភេទសារទូរលេខលេខ១៥ ទាក់ទងទៅនឹងការដកប្រជាជនពីតំបន់បូព៌ាទៅពាយ័ព្យ។ អ៊ីចឹងមានន័យថា នៅក្នុងៗនុ៎ងគឺលោកបានដឹង -- ខ្ញុំអត់ដឹងថាលោកបានដឹង ឬក៏អត់ទេ ពីការជម្លៀសប្រជាជនពីតំបន់បូព៌ាទៅពាយ័ព្យ។ អ៊ីចឹងនៅក្នុងករណីនេះ បើសិនជាលោកអាច តើលោកអាចជួយបំភ្លឺបានឬទេ ថាតើក្រៅពីការជម្លៀសប្រជាជនចេញពីតំបន់បូព៌ា ទៅពាយ័ព្យ តើតំបន់ផ្សេងៗមានការជម្លៀសប្រជាជនចេញពីតំបន់មួយ ទៅតំបន់មួយដែរឬទេ? លោកមានដឹងពីករណីហ្នឹងដែរឬទេ?

[១០:៣១:៥៧]

**ឆ៖** បាទ អំពីករណីសារទូរលេខជម្លៀសប្រជាជនពីបូព៌ា ដូចជាមិនមែនតែពាយ័ព្យទេ ដែលខ្ញុំឃើញថាទៅឧត្តរ ហើយនិងពាយ័ព្យ។ ដូច្នេះគឺប្រជាជនអ៊ីស្លាមហ្នឹង ខ្ញុំបានជម្រាបអង្គសវនាការហើយថា សារទូរលេខហ្នឹង ពុំមែនជាមុខសញ្ញាដែលខ្ញុំបានធ្វើ ខ្ញុំបានបកប្រែទេបាទ។ ហើយក៏និយាយអំពីការជាក់ស្តែងនៅតាមមូលដ្ឋាន គឺខ្ញុំមិនបានដឹងអ្វីទេ ពីព្រោះខ្ញុំធ្វើការតែក្នុងការិយាល័យរបស់ខ្ញុំ។ អ៊ីចឹង

មូលដ្ឋានគេធ្វើអី មិនមែនតែការជម្លៀសទេ សូម្បីតែការសម្រិតសម្រាំងយ៉ាងម៉េច បោសសម្អាតយ៉ាងម៉េច ខ្ញុំក៏ពុំបានដឹងដែរ។ ការពិតជាក់ស្តែងបាទ។ អ៊ីចឹងសូមមិនធ្វើអត្ថាធិប្បាយទេបាទ។

**ប្រធានអង្គជំនុំ៖**

អរគុណសាក្សី អរគុណមេធាវី។ ឥឡូវដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាក ២០នាទី ចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងដប់មួយខ្វះដប់នាទីសូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការ សម្របសម្រួលផ្តល់កន្លែងសម្រាក នៅបន្ទប់រង់ចាំសម្រាប់សាក្សីសម្រាកនៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្តល់សក្ខីកម្មនេះវិញ នៅវេលាម៉ោងដប់មួយខ្វះដប់នាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:៣៣ នាទី ដល់ម៉ោង ១០:៥៣ នាទី)*

[១០:៥៣:០៩]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងផ្តល់វេទិកាជូនទៅក្រុមមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីទទួលសិទ្ធិ សូមបន្តតាំងសំណួរដេញដោលចំពោះសាក្សី។

សូមអញ្ជើញ!

**លោកស្រី ទី ស្រ៊ីនណា៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោកស្រី ទី ស្រ៊ីនណា៖**

**ស៖** លោក សុផង់ ខ្ញុំសូមធ្វើការបន្តសំណួរបន្តទៀត។ កាលពីម្សិលមិញ ខ្ញុំក៏បានស្តាប់ឮនូវចម្លើយរបស់លោកមួយ ពាក់ព័ន្ធជាមួយនឹងការឆ្លើយស្មានៗនៅសហថៅក្រុមស៊ើបអង្កេត។ ពេលហ្នឹង

លោកក៏បានឆ្លើយថា អ្វីដែលលោកបានឆ្លើយស្មានៗហ្នឹងគឺនៅសហាចៅក្រមស៊ើបអង្កេតហ្នឹង គឺមិនអាចយកជាការបានទេ តើលោកចង់មានន័យថា -- សំណួររបស់ខ្ញុំចង់ធ្វើការបញ្ជាក់ថា តើលោកចង់មានន័យថា លោកអត់យកជាការទៅលើចម្លើយរបស់ ដែលលោកបានឆ្លើយទៅសហាចៅក្រមស៊ើបអង្កេតទាំងមូល ឬក៏ជាផ្នែកណាមួយដែលលោកស្មានៗនោះ ឬក៏យ៉ាងម៉េចដែរលោក?

[១០:៥៤:៣១]

**លោក នង សុផង់៖**

**ឆ៖** បាទ ខ្ញុំសូមបញ្ជាក់ឡើងវិញគឺថា អ្វីដែលមាននៅក្នុងសេចក្តីស៊ើបអង្កេត ដែលខ្ញុំនិយាយថា ស្មាន ឬប្រហែល ឬមួយក៏តាមខ្ញុំប៉ាន់ស្មាន អ៊ីចឹង សូមឱ្យអង្គសវនាការទាំងមូលលុបចេញទាំងអស់ចុះបាទ មិនអាចយកជាការបានទេ។

**ស៖** អ៊ីចឹងលោកចង់លុបទាំងមូល ឬក៏ចង់លុបចម្លើយទាំងឡាយណាដែលលោកបានឆ្លើយដោយមានលក្ខណៈប្រាកដប្រជា តើលោកនៅរក្សាដដែល ឬក៏គាត់ចង់លុបទាំងអស់? សូមលោកបញ្ជាក់។

**ប្រធានអង្គជំនុំ៖**

មិនបាច់ឆ្លើយទេ! សាក្សីឆ្លើយច្បាស់ហើយ អ្នកសួរទេមិនច្បាស់ខ្លួនឯង។

**លោកស្រី ទី ស្រ៊ីនណា៖**

សូមអរគុណលោកប្រធាន ដែលបានបំភ្លឺ។ ខ្ញុំសូមធ្វើការបន្តសំណួរ។ ខ្ញុំសូមលើកយកឯកសារលេខ -- សូមអនុញ្ញាតលោកប្រធានលើកយកឯកសារលេខ E3/64 ដែលមានលេខ ERN ជាភាសាខ្មែរ 00328040, និងលេខ ERN ជាភាសាអង់គ្លេស ដែលមានលេខ 00334057, ហើយភាសាបារាំងគឺលេខ 00411707។

**សួរដោយលោកស្រី ទី ស្រ៊ីនណា៖**

**ស៖** នៅក្នុងនុ៎ង ខាងសហព្រះរាជអាជ្ញា គេបានសួរលោកថា “នៅក្នុងសារទូរលេខនេះ -- ”

**លោកស្រី ទី ស្រ៊ីនណា៖**

មុននឹងខ្ញុំធ្វើការតាំងសំណួរ ខ្ញុំសូមអនុញ្ញាតពីលោកប្រធានជាមុនសិន ដើម្បីប្រើប្រាស់ឯកសារនេះតាំងសំណួរទៅសាក្សី។

**ប្រធានអង្គជំនុំ៖**

អនុញ្ញាតសូមអញ្ជើញ!

[១០:៥៦:៣១]

**លោកស្រី ទី ស្រ៊ីនណា៖**

**ស៖** សហព្រះរាជអាជ្ញាបានធ្វើការ អ៎! សហចៅក្រមស៊ើបអង្កេតបានធ្វើការសាកសួរលោកថា "នៅក្នុងសារទូរលេខនេះ មានសំណួរសុំជាយោបល់ តើអ្នកទទួលក្នុងនេះត្រូវឆ្លើយតបទេ?" លោកបានឆ្លើយថា "បញ្ហាខ្លះ បើ ប៉ុល ពត អាចដោះស្រាយបាន គាត់ឆ្លើយតបទៅភ្លាមៗ ប៉ុន្តែបញ្ហាខ្លះមិនអាចក្តាប់បាន ជួនកាលការងារទាក់ទងនឹងគណៈទាំងមូល ដើម្បីសម្រេច។ ដូច្នេះ ប៉ុល ពត អាចកោះប្រជុំគណៈអចិន្ត្រៃយ៍ ដើម្បីសម្រេច"។ តើលោកអាចបញ្ជាក់បានឬទេ ថាតើបញ្ហាខ្លះៗដែល ប៉ុល ពត មិនអាចក្តាប់បានហ្នឹង លោកចង់សំដៅទៅលើបញ្ហាអ្វីដែរ?

**លោក នង សុផង់៖**

**ឆ៖** បាទរឿងនេះគឺជាសារទូរលេខហ្នឹង គឺខ្ញុំបាននិយាយច្បាស់ថា -- មិនច្បាស់តាំងពីដើមទី។ អ៊ីចឹងពាក្យ ដែលខ្ញុំប្រើថា អាចនេះ គឺក្នុងន័យថា ខ្លួនមិនច្បាស់ដែរ អ៊ីចឹងគឺសូមបញ្ហានេះ ក៏សូមឲ្យអង្គសវនាការកុំយកជាការអីបាទ លើចម្លើយរបស់ខ្ញុំនេះ។

**ស៖** សូមអរគុណលោកសាក្សី។ អ៊ីចឹង ខ្ញុំចង់សួរបន្តថា តើតាមបទពិសោធន៍របស់លោកទាក់ទងទៅនឹងការបកប្រែសារទូរលេខ ទាក់ទងទៅនឹងការឆ្លើយពីគណៈ៨៧០ ទៅថ្នាក់មូលដ្ឋាន ក៏ដូចជាថ្នាក់មូលដ្ឋានមកគណៈ៨៧០។ តើកន្លងមក ដែលមានការប្រជុំគណៈអចិន្ត្រៃយ៍ ដើម្បីធ្វើការឆ្លើយតបជាមួយនឹងសារចូលដែរឬទេ?

**ឆ៖** បាទ ខ្ញុំមិនដឹង ពីព្រោះខ្ញុំពុំមែនជាគណៈអចិន្ត្រៃយ៍បាទ។

[១០:៥៩:០១]

**ស៖** សូមអរគុណ។ អ៊ីចឹង ខ្ញុំសូមបន្តទៅសំណួរផ្សេងទៀត។ ទាក់ទងទៅនឹងឯកសារលេខ E3/67 ដែលលោកបានឆ្លើយជាមួយនឹងសហចៅក្រមស៊ើបអង្កេតដដែល ហើយដែលមានលេខ ERN ជាភាសាខ្មែរ 00294545, និង ERN ជាភាសាអង់គ្លេសលេខ 00483973, ជាភាសាបារាំងលេខ 00374940។ នៅក្នុងចំណុចមួយដែលលោកបានឆ្លើយថា "ចំពោះលិខិតរបស់លោក នួន ជា ខ្ញុំក៏ធ្លាប់បកប្រែដែរ តែមិនសូវញឹកញាប់ទេ"។ សំណួររបស់ខ្ញុំចង់សួរថា តើសារដែលលោក នួន ជា ឲ្យលោក

បកប្រែទាក់ទង -- ភាគច្រើនទាក់ទងទៅនឹងបញ្ហាអ្វីដែរ?

**ឆ៖** បាទ លោក នួន ជា លោកទាក់ទងនឹងរឿងប្រជុំសភារបស់លោក។ អ៊ីចឹងគឺលោកមុននឹងធ្វើការប្រជុំ គឺលោកមានអញ្ជើញអស់លោកដែលជាសភាតំណាងរាស្ត្រ តំណាងប្រជាជននៅតាមមូលដ្ឋានហ្នឹងមកប្រជុំបាទ។ គឺដូច្នេះគឺថា១ឆ្នាំមានម្ដងហ្នឹង បាទ មិនមានជាញឹកញាប់ទេ ព្រោះការប្រជុំសភាហ្នឹងមិនមែនធ្វើរាល់ ថ្ងៃរាល់ខែទេ។

[១១:០០:៥០]

**ស៖** លោកថា១ឆ្នាំមានម្ដង ចុះរយៈពេលឆាប់ពី៧៥ ដល់៧៩ ហ្នឹង ការប្រជុំហ្នឹងអាចធ្វើឡើងរយៈពេលប្រហែលជាប៉ុន្មានដងដែរ?

**ឆ៖** បាទ ខ្ញុំបានទទួលតែម្ដងនៅក្នុងអំឡុងឆ្នាំ៧៧ បាទ។ ក្រៅពីហ្នឹង គឺថាដោយសភាពការណ៍ស្រុកទេសហ្នឹងវា ដូច្នេះមិនបានប្រជុំសភាអីទេតាមមើល មានតែម្ដងដែលៗឃើញសាររបស់លោក នួន ជា អញ្ជើញកម្មាភិបាលមូលដ្ឋានហ្នឹងប្រជុំសភាហ្នឹងបាទ។

**ស៖** សូមអរគុណ។

**លោកស្រី ទី ស្រ៊ីនណា៖**

ខ្ញុំសូមអនុញ្ញាតលោកប្រធានប្រើប្រាស់ឯកសារ លេខ D200/9.12 ដែលមានលេខ ERN ជាភាសាខ្មែរ 00294581, ភាសាអង់គ្លេស 00434365 និងភាសាបារាំង 00767253 ដែលឯកសារនេះខ្ញុំគិតថា សាក្សីគាត់មានហើយ ពីព្រោះជាឯកសារដែលខាងសហព្រះរាជអាជ្ញា ប្រគល់ជូនទៅខាងលោកសាក្សីរួចហើយ។ ប៉ុន្តែខ្ញុំចង់មានសំណួរបន្ថែមមួយចំនួនទៅលើសំណួររបស់ខាងសហព្រះរាជអាជ្ញា ដែលសួរកាលពីព្រឹកមិញ។

[១១:០២:៣៧]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

**លោកស្រី ទី ស្រ៊ីនណា៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោកស្រី ទី ស្រ៊ីនណា៖**

**ស៖** ទាក់ទងទៅនឹងគំនូសបំព្រួញរបស់លោក ខ្ញុំមានឃើញដាក់ទាក់ទងទៅនឹងគណៈ៨៧០

គណៈប្រធានរដ្ឋ សភាតំណាងប្រជាជន។ ខ្ញុំចង់សួរថាតើរវាងផ្នែកនីមួយៗហ្នឹង គេធ្វើការទំនាក់ទំនងគ្នាទៅលើសារទូរលេខ -- តើធ្លាប់មានដែលទំនាក់ទំនងលើសារទូរលេខ ឬក៏គេឆ្លើយឆ្លងគ្នាយ៉ាងដូចម្ដេចដែរ? លោកអាចជួយពន្យល់ជូនអង្គសវនាការបានដែរឬទេ ទៅលើចំណុចនេះ?

[១១:០៣:៣១]

**ឆ៖** បាទ និយាយអំពីកិច្ចទំនាក់ទំនងរវាង៨៧០ គណៈប្រធានរដ្ឋ និងសភាតំណាងប្រជាជន។ ខ្ញុំមិនដែលឃើញលោកចេញជាសារទូរលេខឲ្យទៅកោះហៅប្រជុំអីទេ ពីព្រោះថាអស់លោកទាំងអស់នោះនៅភ្នំពេញស្រាប់។ អ៊ីចឹងគឺបើលោកចង់ទំនាក់ទំនងគ្នាអី គឺជាការងាយបំផុត មិនចាំបាច់ប្រើទូរលេខសម្ងាត់របស់យើងខ្ញុំទេបាទ។

**ស៖** អ៊ីចឹងខ្ញុំសូមសួរបន្តទៀត ទាក់ទងទៅនឹងការឆ្លើយបំភ្លឺរបស់លោក លោកថាកន្លែងលោកបើតាមស្ដាប់ចាប់ពីថ្ងៃ២៩ រហូតដល់ម្សិលមិញ រហូតដល់ព្រឹកនេះ ភាគច្រើនគឺពាក់ព័ន្ធជាមួយនឹងការឆ្លើយឆ្លងសារទូរលេខនៅក្នុងថ្នាក់ក្នុងស្រុក។ សំណួររបស់ខ្ញុំចង់សួរបញ្ជាក់ ថាតើចំពោះករណីសារទូរលេខដែលគេឆ្លើយឆ្លងរវាងប្រទេសក្រៅជាមួយនឹង -- តើគេធ្វើយ៉ាងដូចម្ដេចដែរ? មាន -- តើសារទូរលេខដែលមកពីប្រទេសក្រៅហ្នឹងមានបញ្ជូនមកកន្លែងគណៈ៨៧០ ដែរឬទេ?

**ឆ៖** រឿងទាក់ទងខាងក្រៅប្រទេស ខ្ញុំក្ដាប់មិនបានអស់ ខ្ញុំមិនដឹងអស់។ ដូច្នេះ ខ្ញុំមិនមានលទ្ធភាពបញ្ជាក់ជូនលោកស្រីបានទេបាទ។

**ស៖** សូមអរគុណ។ ចុះទាក់ទងទៅនឹងក្រសួងការបរទេស។ តើក្រសួងការបរទេសដែលមានបញ្ជូនសារទូរលេខទៅគណៈ៨៧០ ដោយឆ្លងកាត់តាមកន្លែងរបស់លោក ឬមួយក៏គេបញ្ជូនដោយផ្ទាល់ទៅគណៈ៨៧០តែម្ដង ដែរឬទេ?

[១១:០៦:០០]

**ឆ៖** បាទ ក្រសួងការបរទេសក៏នៅភ្នំពេញស្រាប់។ ឯការទាក់ទងតាមទូរលេខជាមួយខាងក្រុមខ្ញុំ អត់មានទេបាទ។

**ស៖** បើមិនមាន តើភាគច្រើនគេធ្វើការទំនាក់ទំនងគ្នាយ៉ាងដូចម្ដេចដែររវាងក្រសួងការបរទេសជាមួយនឹងគណៈ៨៧០?

**ឆ៖** បាទ ខ្ញុំមិនដឹងបាទ។

**ស៖** អ៊ីចឹងខ្ញុំសូមសួរថា តើនៅក្រសួងការបរទេស តើគេមានផ្នែកបកប្រែសារទូរលេខរបស់គេ

ផ្ទាល់ ឬយ៉ាងម៉េច លោក?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយ! សូមអញ្ជើញលោកមេធាវីការពារក្ដីលោក អៀង សារី!

[១១:០៧:២៤]

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណលោកប្រធាន សូមជម្រាបសួរអស់លោក លោកស្រីទាំងអស់ទាំងនៅក្នុង និងនៅក្រៅសាលសវនាការ។ សំណួរនេះត្រូវបានគេសួរកាលពីម្សិលរួចមកហើយ។ ហើយលោកសាក្សី ក៏បានឆ្លើយទៅនឹងសំណួរនោះ។ ហើយនៅពេលនោះ គឺមានការចោទ -- ផ្អាកដោយខាងព្រះរាជអាជ្ញា។ ដូច្នេះ ខ្ញុំគិតថា យើងមិនចាំបាច់ត្រូវសួរសាជាថ្មីម្ដងទៀតទេ ព្រោះគាត់បានឆ្លើយកាលពីម្សិលមិញរួចទៅហើយ។ សូមអរគុណ។

**លោកស្រី ទី ស្រ៊ុនណា៖**

សូមជម្រាបលោកប្រធាន។ ទាក់ទងទៅនឹងសំណួរនេះ ខ្ញុំគ្រាន់តែស្នើសុំធ្វើការបញ្ជាក់បន្ថែម។ ថាតើមានការ -- នៅក្នុងក្រសួងនីមួយៗហ្នឹងមានការបកប្រែសារទូរលេខដោយផ្ទាល់របស់គេ ឬក៏យ៉ាងម៉េច បានជាមិនមានការឆ្លងកាត់រវាងក្រសួងការបរទេស នៅក្នុងករណីដែលសារដែលចូលមកពីបរទេសមិនមានការឆ្លងកាត់ទៅគណៈ៨៧០។ ដូច្នេះខ្ញុំគិតថា ចំណុចនេះគឺជាចំណុចសំខាន់មួយ ដែលអង្គជំនុំជម្រះគួរតែបានដឹងអំពីបញ្ហានេះ។ សូមអនុញ្ញាតលោកប្រធានឲ្យសាក្សីជួយបំភ្លឺ។

**លោក ម៉ៃខល កាណាវាស៖**

ខ្ញុំសូមជម្រាបលោកប្រធាន ខ្ញុំមិនមែនលើកឡើងដើម្បីជជែកដេញដោលដែរ ព្រោះថានេះគឺជាភស្តុតាងដែលសាក្សីបានផ្តល់សក្ខីកម្មរួចទៅហើយ។ ដូច្នេះហើយ ខ្ញុំជំទាស់នូវការលើកមតិយោបល់នានា។ គាត់ព្យាយាមចង់ឲ្យមានការបង្ហាញសក្ខីកម្មថា តើអាច ឬមិនអាច ដែលមានកើតឡើងនៅក្រសួងការបរទេស? ហើយលោកសាក្សី គាត់មិនមានអ្វីឲ្យច្បាស់លាស់ទាក់ទងនឹងក្រសួងការបរទេសនោះឡើយ។ ដូច្នេះហើយ គឺមិនគួរឲ្យមានការទាយស្មានថា តើមានអ្វីអាចកើតឡើង ឬមិនកើតឡើងនៅក្រសួងការបរទេសនោះឡើយ។ សូមអរគុណ។

[១១:០៩:២៩]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយបន្ទាប់ពីអង្គជំនុំជម្រះបានជម្រាបរំឭកអំពីករណីយកិច្ចរបស់សាក្សីមក។ អង្គជំនុំជម្រះកត់សម្គាល់ឃើញថា សាក្សីរូបនេះបានខិតខំព្យាយាមក្នុងការស្តាប់ទៅនឹងសំណួរ ហើយឆ្លើយតបទៅនឹងសំណួរបានត្រឹមត្រូវ។ រហូតដល់គាត់កែនូវអ្វីដែលគាត់បានឆ្លើយដោយស្មានៗ កាលពីលើកមុននៅចំពោះមុខអ្នកស៊ើបអង្កេតនៃចៅក្រមស៊ើបអង្កេតទៀតផង។ មានន័យថាគាត់កំពុងតែផ្តល់នូវសក្ខីកម្មដ៏ត្រឹមត្រូវមួយដែលមិនឆ្លើយនូវអ្វីដែលស្មានៗទេ ម្សិលមិញយើងបានកត់សម្គាល់ឃើញថានៅមុនពេលអាហារថ្ងៃត្រង់មានចម្លើយមួយចំនួនដែលស្មានៗ អ៊ីចឹងហើយបានជាយើងទៅពិភាក្សាកត់សម្គាល់អំពីបញ្ហានេះ ហើយចូលត្រឡប់មកវិញយើងបានណែនាំដល់សាក្សីឱ្យអនុវត្តឱ្យបានពេញលេញនូវភារកិច្ចរបស់ខ្លួនឆ្លើយតបទៅនឹងសំណួរនូវអ្វីដែលខ្លួនបានដឹង បានឮ បានឃើញ ចងចាំយ៉ាងទាបបំផុតក៏បទពិសោធន៍ដែលគាត់បានជួបប្រទះ ឬក៏បានធ្វើការសង្កេតពាក់ព័ន្ធទៅនឹងព្រឹត្តិហេតុ ហេតុការណ៍ទាំងឡាយដែលពាក់ព័ន្ធនឹងសំណួរ ដែលសួរ នេះគឺច្បាស់លាស់ហើយ។ ហើយសេចក្តីជំទាស់នេះ គឺមិនមានសំអាងហេតុច្បាស់លាស់ទេ សាក្សីអាចឆ្លើយតបទៅនឹងសំណួរដែលសួរ ពីព្រោះសំណួរនេះគឺមានការប្លែកពីសំណួរកាលពីម្សិលមិញ។

**លោក នង សុផង់៖**

**ឆ៖** បាទ អំពីការទំនាក់ទំនងរវាងក្រៅប្រទេស ក្នុងសម័យនោះ ខ្ញុំដឹងថាមានការដាក់ទំនាក់ទំនងទូតជាមួយក្រៅប្រទេស តែការទាក់ទងខាងទូរលេខ ពីព្រោះខ្ញុំមិនបានទទួលទិសណាមួយដែលជាការងាររបស់ក្រសួងការបរទេស។ អ៊ីចឹង ខ្ញុំសូមសិទ្ធិមិនធ្វើអត្ថាធិប្បាយអ្វីទាំងអស់បាទ។

[១០:១២:០៨]

**សួរដោយលោកស្រី ទី ស្រ៊ីនណា៖**

**ស៖** សូមអរគុណចំពោះការបំភ្លឺ។ ខ្ញុំសូមធ្វើការបន្តសំណួរបន្តទៀត ទាក់ទងទៅនឹងម្សិលមិញលោកបានលើកអំពីគណៈ៨៧០ គឺជាគណៈមជ្ឈិម។ អ៊ីចឹង ខ្ញុំចង់សួរថា តើគណៈ៨៧០ហ្នឹង មានតែ -- មានសមាជិកចំនួនប៉ុន្មាននាក់ដែរ លោកអាចដឹងពីបញ្ហានេះដែរឬទេ?

**ឆ៖** បាទ ខ្ញុំមិនដឹងថា ៨៧០ហ្នឹង មានសមាជិកប៉ុន្មានទេ ហើយក៏មិនដឹងថាមាននរណាខ្លះដែលជាគណៈ៨៧០ ហ្នឹង។ បាទ មិនដឹងទេបាទ។

**ស៖** សំណួររបស់ខ្ញុំទាក់ទងទៅនឹង -- សុំបកក្រោយបន្តិចដោយសារតែកាលពីថ្ងៃទី២៩ ខែ

សីហា ឆ្នាំ២០១២ ហ្នឹង លោកបានឆ្លើយជាមួយនឹងខាងសហព្រះរាជអាជ្ញា ដោយលោកបានលើកឡើងថា ទាក់ទងទៅនឹងសមរភូមិមុខ និងសមរភូមិក្រោយ។ អ៊ីចឹងសំណួររបស់ខ្ញុំចង់សួរថា តើរាល់ការសម្រេច ឬដោះស្រាយបញ្ហាអ្វីមួយរបស់សមរភូមិមុខធ្វើទៅ អាចធ្វើទៅបានដោយពុំចាំបាច់ឆ្លងកាត់ការឆ្លងឆ្លើយសួរយោបល់អំពីសមរភូមិក្រោយដែរ ឬក៏ចាំបាច់ត្រូវតែមានការស្នើសុំ ឬក៏រាយការណ៍សុំជាយោបល់ពីសមរភូមិក្រោយជាមុន?

[១១:១៤:៣៧]

**ឆ៖** បាទ ការងារដែលខ្ញុំធ្វើនៅសមរភូមិក្រោយ គឺមានតែសារទូរលេខ ជាដំណឹងជ័យជម្នះដែលគេប្រយុទ្ធគ្នានៅសមរភូមិមុខ រួចហើយគេរាយការណ៍ដើម្បីឲ្យខាងវិទ្យុផ្សាយសំឡេងគេផ្សាយ បាទ អានេះការងារ។ ឯការងារអ្វីៗនៅមូលដ្ឋានសមរភូមិក្រោយនេះ ខ្ញុំហាក់ដូចជាមិនមានការណែនាំអ្វីពីខាងមុខទៅក្រោយ ពីក្រោយមកមុខសោះ នៅក្នុងរយៈកាលដែលខ្ញុំនៅក្នុងព្រៃចេក មើលពី៧៤ ដល់ -- បាទ ជិតកន្លះឆ្នាំហ្នឹង ដូចមិនមានសារទូរលេខអីឆ្លើយឆ្លងអី ពីមុខទៅក្រោយ ពីក្រោយទៅមុខទេច្រើនទេបាទ មិនមានទេ ភាគច្រើនមានតែដំណឹងដែលត្រូវផ្សាយហ្នឹង។

[១១:១៦:០៨]

**ស៖** សំណួររបស់ខ្ញុំសូមសួរបន្ត ទាក់ទងទៅនឹង -- ឆ្លងតាមបទពិសោធន៍របស់លោក នៅក្នុងផ្នែកបកប្រែសារទូរលេខនេះ ថាតើកន្លងមកដែលមានតំបន់ ឬក៏ភូមិភាគណាមួយមិនបានរាយការណ៍មន្ទីរគណៈ៨៧០ ដែរឬទេ? បើមិនមានការរាយការណ៍ តើមានប្រតិកម្ម -- តើគណៈ៨៧០ ដឹងពីបញ្ហានោះដែរឬទេ? ហើយបើដឹង តើគណៈ៨៧០ មានប្រតិកម្មទៅលើរឿងហ្នឹងយ៉ាងដូចម្ដេច?

**ឆ៖** បាទ លើរបាយការណ៍ពីក្រោមមកលើ ពីលើទៅក្រោម ក្នុងសម័យហ្នឹងហាក់ដូចជាមិនមានអ្វីដែល៨៧០ ធ្វើការមានប្រតិកម្មអ្វីនៅលើរបាយការណ៍ដែលគេមិនបានរាយការណ៍ ដូចជាមិនមានឃើញអ្វីទេបាទ គឺខ្ញុំមិនដែលបានឃើញការស្ដីបន្ទោស ឬមួយក៏ការចោទប្រកាន់ពីលើដោយសារតែរឿងធ្វើរបាយការណ៍នោះទេ។ បាទ អត់មានបាទ។

**ស៖** សូមអរគុណ។ ខ្ញុំសូមបញ្ជាក់លោកមួយទៀត ជាទាក់ទងនឹងចម្លើយរបស់លោក ដែលបានឆ្លើយបំភ្លឺនៅចំពោះមុខអង្គសវនាការកាលពីម្សិលមិញ។ លោកបានឆ្លើយថា ជាទូទៅ សារដែលគេធ្វើចូលហ្នឹង គឺ“គោរពចូលបងជាទីគោរព” ហើយសារមួយប្រភេទទៀត គឺ “គោរពចូលគណៈ៨៧០”។ អ៊ីចឹង សំណួររបស់ខ្ញុំចង់សួរថា តើនៅក្នុងករណីដែល ប៉ុល ពត ដែលគាត់អវត្តមាន តើនរណាជាមាន

សិទ្ធិទទួលសារទូរលេខនោះ ជំនួសគាត់? ហើយបុគ្គលនោះ មានសិទ្ធិឆ្លើយតបសារទូរលេខនោះដែរទេ?

[១១:១៨:៤០]

**ឆ៖** បាទ នៅសម័យនុំង គឺខ្ញុំជាក្រុមបកប្រែមែន ប៉ុន្តែដូចខ្ញុំបានបញ្ជាក់ជូនលោកហើយ គឺមានបកខាងក្នុង មានខាងក្រៅ។ អ៊ីចឹង ឯខ្ញុំតួនាទីខ្ញុំ គឺនៅខាងក្រៅ។ អ៊ីចឹង គឺអ្វីដែលខ្ញុំបកប្រែហើយ ខ្ញុំផ្ញើទៅខាងក្នុងគេចាត់ចែង។ ខ្ញុំមិនដឹងថា អ្នកណាដែល -- ពេលដែលអវត្តមានរបស់ ប៉ុល ពត ខ្ញុំមិនដឹងថាអ្នកណាគេមានសិទ្ធិឆ្លើយតបនោះទេ។ បាទ គឺខ្ញុំអត់ដឹង។

**ស៖** ខ្ញុំសូមសួរសំណួរបន្តទៀត ទាក់ទងទៅនឹងស្ថានភាពនៅទីក្រុងភ្នំពេញ។ ចាប់តាំងពីលោកមករស់នៅនិងធ្វើការនៅទីក្រុងភ្នំពេញ តើលោកដែលមានកត់សម្គាល់ឃើញហេតុការណ៍ណាមួយដែលគួរឲ្យកត់សម្គាល់ ដែលលោកចង់ជម្រាបជូនអង្គសវនាការដែរឬទេ?

**ឆ៖** បាទ ហេតុការណ៍ដែលខ្ញុំបានជួបប្រទះនៅក្នុងរយៈកាលដែលខ្ញុំរស់នៅភ្នំពេញ គឺថាតាំងពីចុង៧៥ រហូតដល់ចុង៧៦ នេះ មានសភាពប្រក្រតី ក៏ប៉ុន្តែចាប់ពីចុងឆ្នាំ៧៧ និងដើមឆ្នាំ៧៨, ៧៩ នេះ ភ្នំពេញពុំមានសន្តិសុខគ្រប់គ្រាន់ទេ គឺស្ថិតនៅក្នុងសភាពប្រុងប្រយ័ត្នជាប់។ ខ្ញុំក៏បានឃើញរបាយការណ៍ពីខាងមូលដ្ឋានមកដែរ អំពីការវាយលុក ឬមួយក៏ការជម្លោះគ្នាហ្នឹងមកពីខាងព្រំដែនខាងកើត ហើយក៏ខ្ញុំបានឃើញយុទ្ធជនដែលត្រូវរបួសដេកពេញៗមន្ទីរពេទ្យ ហើយក៏ខ្ញុំបានឃើញអ្វីដែលប្រជាជនរត់ភៀសសឹកមកពីបូព៌ា ខ្លះមកដល់តាមមាត់ទន្លេ ខ្លះហួសពីភ្នំពេញទៅទៀតក៏មាន។ ហើយខ្ញុំបានឮ បានឃើញនៅក្រុងភ្នំពេញក្នុងអំឡុងឆ្នាំ៧៨ ក៏មានវិទ្ធេទកម្មនៅក្នុងទីក្រុងភ្នំពេញ មានការបោកគ្រាប់បែកសម្លាប់ទូតបរទេស ហើយនិងមានការធ្វើឃាតកម្មលើកម្មាភិបាល។ នេះគឺនៅក្នុងឆ្នាំ៧៨ គឺខ្ញុំមិនមានការរស់នៅដោយសប្បាយរីករាយទេ មានការបារម្ភជាប់បាទ។ នេះជាអ្វីដែលជាចំណាប់អារម្មណ៍នៅក្នុងរយៈកាលហ្នឹង។

[១១:២២:៣៤]

**ស៖** ខ្ញុំសូមបញ្ជាក់មួយទៀត លោកថា មានការបោកគ្រាប់បែកហ្នឹង តើស្ថានភាពនៃការបោកគ្រាប់បែកហ្នឹង គឺខាងណាជាអ្នកបោកគ្រាប់បែកដែរ ក្នុងពេលនោះ? នៅក្នុងប្រហែលជាក្នុងអំឡុងពេលណាដែរ លោកអាចរកនឹកមើលថា តើវានៅស្ថិតនៅក្នុងអំឡុងពេលណាដែរ?

**ឆ៖** បាទ ខ្ញុំមិនដឹងថា ផ្នែកខាងណាទេ ដែលបង្កឲ្យមានភេរវកម្មហ្នឹង ហើយខ្ញុំចងចាំគឺថាប្រហែលនៅក្នុងឆ្នាំ៧៨ បាទ គឺថាមុនដែលការរំដោះ ៧មករា បាទ។

**ស៖** សំណួររបស់ខ្ញុំសូមសួរមួយសំណួរ -- សូមសួរបន្តទៀតទាក់ទងទៅនឹងការកម្ទេចខ្មាំងផ្ទៃក្នុងជួរបក្ស តើដែលមានសារទូរលេខរាយការណ៍អំពីការបោសសម្អាតខ្មាំងក្នុងជួរបក្សនេះដល់គណៈ៨៧០ដែរឬទេ? បើសិនជាករណី -- សូមៗលោកឆ្លើយសិន!

[១១:២៣:៥៤]

**ឆ៖** បាទ អំពីរឿងបោសសម្អាត រឿងកម្ទេចអី លោកស្រីក៏បានឃើញដែលព្រះរាជអាជ្ញាបានឲ្យច្រើនណាស់ រឿងសារ រឿងនិយាយពីរឿងផ្ទៃក្នុង ពីរឿងអី រឿងសម្រិតសម្រាំង រឿងបោសសម្អាតរឿងកម្ទេចអី គឺច្រើនណាស់ សារមួយកំភ្លូសនេះ មានទាក់ទងនឹងរឿងហ្នឹង។ ដូច្នេះ ខ្ញុំមិនបាច់និយាយក៏លោកស្រីអាចឃើញដោយផ្ទាល់ខ្លួនឯងបានហើយ។ ប៉ុន្តែអត្ថន័យដែល នៃការបោសសម្អាតពិតជាក់ស្តែងនៃការសម្រិតសម្រាំងជាក់ស្តែង ឬការកម្ទេចជាក់ស្តែង ខ្ញុំមិនដែលឃើញផ្ទាល់នឹងភ្នែកខ្លួនឯងទេបាទ។

**ប្រធានអង្គជំនុំ៖**

លោកស្រីមេធាវី គប្បីតម្រង់នូវសំណួរដែលពាក់ព័ន្ធ និងទំនងជាសំណួរនោះសាក្សីទំនងជាដឹង សំណួរជាច្រើនដែលលោកស្រីតាំងសំណួរចំពោះសាក្សី គឺសំណួរមួយចំនួនសាក្សីមិនដឹងទាល់តែសោះអីចឹងការចំណាយរបៀបសួរនេះ គឺអាចចំណាយពេលវេលាបាត់បង់ពេលវេលាច្រើន។ ហើយពេលវេលាទំនងជានៅតែដូចជាកន្លះម៉ោងទៀតទេ គឺ៣៧នាទីទៀតតែប៉ុណ្ណោះ សម្រាប់ភាគីមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី។ សូមជ្រាប។

**លោកស្រី ទី ស្រ៊ីនណា៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោកស្រី ទី ស្រ៊ីនណា៖**

**ស៖** ខ្ញុំមានសំណួរចុងក្រោយមួយ ទាក់ទងទៅនឹងទំនាក់ទំនងរវាងលោក នួន ជា ជាមួយនឹង ប៉ុល ពល ក៏ដូចជាទំនាក់ទំនងរវាងលោក ខៀវ សំផន ជាមួយនឹង ប៉ុល ពត ក៏ដូចជាទំនាក់ទំនងរវាង អៀង សារី ជាមួយនឹង ប៉ុល ពត។ តើលោកធ្លាប់ដែលដឹងអំពីទំនាក់ទំនងនេះ ដូចថា ធ្លាប់ឮគេនិយាយអំពីទំនាក់ទំនងរបស់គាត់យ៉ាងម៉េចដែរ? តើលោកធ្លាប់ឮគេនិយាយដែរឬទេ ឬមួយក៏ឆ្លងកាត់តាមបទពិសោធន៍របស់លោក ដែលធ្វើការឲ្យបក្សកុម្មុយនីស្តកម្ពុជាប្រជាធិបតេយ្យ ជាពិសេសគឺនៅក្នុងគណៈ៨៧០នេះ តើលោកដែលធ្លាប់ឮពីបញ្ហានេះដែរទេ? ថាតើទំនាក់ទំនងនេះយ៉ាងម៉េចដែរ?

**លោក នង សុផង់៖**

**ឆ៖** បាទ រឿងទំនាក់ទំនងរបស់អស់លោកមេដឹកនាំទាំងអស់នេះ ខ្ញុំមិនបានដឹងទេ ព្រោះក្នុងសម័យហ្នឹងខ្ញុំគឺជាអ្នកតូចតាច។ ដូច្នេះកិច្ចការរបស់អស់លោកអ្នកដឹកនាំធំៗ ខ្ញុំមិនអាចដឹងបានទេបាទ។

**ស៖** សូមអរគុណចំពោះការឆ្លើយរបស់លោក។

[១១:២៦:៣៤]

**លោកស្រី ទី ស្រ៊ុនណា៖**

ហើយជាកិច្ចបន្តនេះ ខ្ញុំសូមផ្ទេរវេទិកាទៅឲ្យសហមេធាវីអន្តរជាតិ នឹងធ្វើការតាំងសំណួរបន្តទៀតទៅលោក។ សូមអរគុណចំពោះការខំប្រឹងប្រែងឆ្លើយនឹងសំណួររបស់ខ្ញុំ។ សូមអរគុណ។ សូមអរគុណលោកប្រធាន។

**កញ្ញា ហ្វីលីពីន ស៊ុតហ្ស៍៖**

សូមជម្រាបសួរលោកប្រធាន ជម្រាបសួរលោក លោកស្រីចៅក្រម ជម្រាបសួរភាគីទាំងអស់។

**សួរដោយកញ្ញា ហ្វីលីពីន ស៊ុតហ្ស៍៖**

**ស៖** ជម្រាបសួរលោកសាក្សី នង សុផង់ ខ្ញុំឈ្មោះ ហ្វីលីពីន ស៊ុតហ្ស៍។ ខ្ញុំជាមេធាវីតំណាងឲ្យដើមបណ្ដឹងរដ្ឋប្បវេណី។ ខ្ញុំសូមសួរសំណួរលោកមួយចំនួន។

ជាបឋម ខ្ញុំចង់ត្រឡប់មកនិយាយដោយខ្លី អំពីរយៈពេលមុនឆ្នាំ៧៥ ជាពិសេសពាក់ព័ន្ធទៅនឹងចម្លើយរបស់លោកដែលបានឆ្លើយទៅសហព្រះរាជអាជ្ញា កាលពីថ្ងៃទី២៩ ខែសីហា។ ខ្ញុំសូមអានទូវប្រតិចារឹកសវនាការ។ លោកបានិយាយថា "អំពីការរៀបចំវ៉ៃរំដោះក្រុងភ្នំពេញពី លន់ នល់ ខ្ញុំទទួលសារ ហើយនិងបានទទួលការណែនាំអំពីការរៀបចំឲ្យកងទ័ពយើងវ៉ៃខាងណា អីខាងណា។ គឺថាមានពីការរៀបចំជាផែនការ"។ តើលោកអាចពន្យល់បញ្ជាក់បន្ថែមអំពីចំណុចនេះទេ ថាតើលោកទទួលបទបញ្ជា ឬក៏ការណែនាំហ្នឹង ជាការបញ្ជាយ៉ាងម៉េច ហើយទទួលការបញ្ជាណែនាំហ្នឹងពីអ្នកណាដែរ?

[១១:២៨:២៤]

**លោក នង សុផង់៖**

**ឆ៖** បាទ ចំពោះការវ៉ៃ -- រៀបចំផែនការវ៉ៃលុកក្រុងភ្នំពេញ ខ្ញុំបានបញ្ជាក់អង្គសវនាការថា ខ្ញុំមិនដឹង ហើយក៏មិនបានឃើញទូរលេខដែលអង្គការបញ្ជាឲ្យកងទ័ពណាវ៉ៃខាងណាៗអីគឺគ្មានទេ។ ពីព្រោះខ្ញុំធ្វើការនៅក្នុងសមរភូមិក្រោយ ឯការរៀបចំផែនការវ៉ៃភ្នំពេញពីខាងណាៗ ដូចខ្ញុំបានជម្រាបអង្គ

សវនាការហើយ គឺលោក ប៉ុល ពត ពេលហ្នឹងគឺលោកទៅសមរភូមិខាងលិចភ្នំពេញ។ ដូច្នេះ ការរៀបចំដាក់ផែនការវ៉ៃក្រុងភ្នំពេញ លោកមិនបាច់ធ្វើសារទូរលេខអ្វីទេ ពីព្រោះកងពលទាំងអស់ មុខព្រួញគ្រប់ទាំងអស់ គឺវានៅជុំវិញភ្នំពេញស្រាប់ហើយ។ ឯខ្ញុំនៅខាងក្រោយនេះអត់ដឹងទេបាទ។ ហើយក៏មិនមានសារទូរលេខណែនាំពីរឿងវ៉ៃ លន់ នល់ ពីខាងណាៗអី គឺគ្មានទេមកដល់កន្លែងការិយាល័យខ្ញុំនៅព្រៃចេកហ្នឹង។

**ស៖** សូមអរគុណ។ ខ្ញុំមិនសំដៅទៅលើទូរសារទេ ក៏ប៉ុន្តែខ្ញុំសំដៅទៅលើចម្លើយរបស់លោកនៅក្នុងសវនាការនេះ។ ក៏ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ក៏ខ្ញុំសូមចូលទៅសំណួរបន្ទាប់មកទៀត ខ្ញុំចង់សួរសំណួរមួយចំនួនពាក់ព័ន្ធទៅនឹងសមាជិកក្រុមគ្រួសាររបស់លោក។ កាលពីសវនាការថ្ងៃទី២៩ ខែសីហា លោកបានរៀបរាប់យ៉ាងខ្លីអំពីឪពុកម្តាយរបស់លោក នៅពេលដែលសហព្រះរាជអាជ្ញាសួរលោក។ តើលោកអាចបញ្ជាក់ឲ្យបានច្បាស់ អំពីបងប្អូនរបស់លោក អ៊ំ ពូ មីង មា ឬក៏បងប្អូនជីដូនមួយអ្វីទេ?

[១១:៣០:៤៣]

**ប្រធានអង្គជំនុំ៖**

មិនចាំបាច់រៀបរាប់ទេ សំណួរនេះក្រៅអង្គហេតុ មិនពាក់ព័ន្ធនឹងអង្គហេតុត្រូវធ្វើសវនាការទេ។ ការសួរសាក្សី គឺប្រធានអង្គជំនុំជម្រះសួរនូវអត្តសញ្ញាណពាក់ព័ន្ធនឹងសាក្សីរួចហើយ។ កម្រិតសមស្របតែអង្គជំនុំជម្រះបានរៀបចំសំណួរសួរ ពាក់ព័ន្ធទៅនឹងសាវតារជាតិរបស់សាក្សីនៅចំពោះមុខអង្គជំនុំជម្រះ។

**កញ្ញា ហ្វីលីពីន ស៊ុតហ្ស៍៖**

លោកប្រធាន ខ្ញុំព្យាយាមកំណត់ឲ្យច្បាស់អំពីក្រុមគ្រួសាររបស់គាត់ ដើម្បីឲ្យដឹងថា តើគាត់មានសមាជិកអ្វីខ្លះ ហើយបន្ទាប់មក ខ្ញុំចង់ដឹងថា តើក្នុងសម័យនោះគាត់មានការទាក់ទងគ្នា ជាមួយនឹងសមាជិកគ្រួសាររបស់គាត់ដែរឬទេ នៅក្នុងចន្លោះ៧៥-៧៩ នោះ ពីព្រោះនេះជាចម្លើយរបស់គាត់នៅក្នុងសវនាការនេះ។

**ប្រធានអង្គជំនុំ៖**

សាក្សីមិនបាច់ឆ្លើយតបទេ! សំណួរនេះមិនចាំបាច់ មិនមានរួមវិភាគទានអីស្វែងរកការពិតនោះឡើយ។

**សួរដោយកញ្ញា ហ្វីលីពីន ស៊ុតហ្ស៍៖**

**ស៖** លោក នង សុផង់ សួរសំណួរមួយចំនួនពាក់ព័ន្ធទៅនឹងសភាពការណ៍នៅទីក្រុងភ្នំពេញនៅចន្លោះឆ្នាំ៧៥ និង ឆ្នាំ៧៩ លោកបានឆ្លើយថា លោកបានមកដល់ទីក្រុងភ្នំពេញចុងឆ្នាំ១៩៧៥។ តើលោកអាចរៀបរាប់អំពីស្ថានភាពនៅទីក្រុងនោះ នៅចុងឆ្នាំ៧៥ រហូតទៅដល់ឆ្នាំ -- រហូតទៅដល់ដើមឆ្នាំ៧៩ បានដែរឬទេ?

[១១:៣២:៤២]

**ឆ៖** បាទ អ្វីដែលខ្ញុំបានធ្វើចំណាប់អារម្មណ៍ ខ្ញុំក៏បានបញ្ជាក់ជូនអង្គសវនាការរួចអស់ហើយថា អ្វីដែលចម្លែកក្នុងចិត្តខ្ញុំ ពេលដែលខ្ញុំចូលភ្នំពេញ គឺឃើញថា មាន -- ភ្នំពេញមានសភាពស្ងប់ស្ងាត់ មិនមានប្រជាជនច្រើនកុះករដូចឥឡូវនេះទេបាទ។ នេះជាចំណុចដែលខ្ញុំបានបញ្ជាក់រួចមកហើយ។ ឯក្រៅពីហ្នឹងគឺថា អ្វីដែលធ្វើឲ្យប្លែកក្នុងអារម្មណ៍របស់ខ្ញុំ ក្នុងសម័យនោះគឺ មិនមានទេបាទ។ ប្លែកគឺត្រង់ដែលថា អាចុងឆ្នាំ៧៧ និង៧៨ ហ្នឹងហើយដែលធ្វើឲ្យខ្ញុំមានអារម្មណ៍ខុសប្រក្រតី គឺមានការព្រួយបារម្ភច្រើន ហើយក៏ខ្ញុំបាននិយាយរួចអស់ហើយបាទ។

**ស៖** តើលោកអាចបញ្ជាក់ឲ្យបានច្បាស់បន្តិចទេ ថាតើមានអ្នកណាខ្លះដែលមានវត្តមាននៅទីក្រុងភ្នំពេញនោះ តើជាមនុស្សប្រភេទណាដែរ ដែលអាចមានវត្តមាននៅទីក្រុងភ្នំពេញនៅសម័យនោះៗ?

**ឆ៖** បាទ ខ្ញុំបានឃើញមានកម្មកររោងចក្រ មានកងទ័ព -- បាទ ភាគច្រើនគឺឃើញកម្មកររោងចក្រតែម្តងបាទ ដែលលោកខិតខំធ្វើការ ដើម្បីផលិតសម្ភារៈផ្សេងៗជូនទៅសហករណ៍ នៅតាមមូលដ្ឋាន។ នេះហើយដែលជាសកម្មភាពដែលខ្ញុំបានឃើញ ប្រជាជនភាគច្រើនគឺ ភាគច្រើនជាកម្មករបាទ។

[១១:៣៥:០៤]

**ស៖** សូមអរគុណ។ ចុះចំពោះលោក តើលោកអាចធ្វើដំណើរទៅណាមកណាទៅកន្លែងផ្សេងៗបានញឹកញាប់ដែរឬទេ?

**ឆ៖** បាទ មិនជាញឹកញាប់ទេ ពីព្រោះកាលហ្នឹង ជាវិន័យ គឺមានការឲ្យយើងត្រូវគោរពភារកិច្ចរបស់យើង ម្យ៉ាងគឺខ្ញុំទទួលការងារមួយហ្នឹងផង ខ្ញុំមិនអាចដើរចេញចោលកន្លែងខ្ញុំបានយូរទេ។ ខ្ញុំមានឱកាសគឺពេលណាដែលមានការចាត់តាំងឲ្យខ្ញុំទៅណែនាំពន្យល់គេ បញ្ជោបច្ចេកទេសដូចជាខ្ញុំបាន

លើកឡើងរៀបរាប់ហើយ ខ្ញុំ អង្គភាពមូលដ្ឋានណាដែលមិនមានការយល់ដឹងខាងបច្ចេកទេសអីខ្ញុំចេញទៅទំនាក់ទំនងគេ។ ឯក្នុងសម័យនោះ សូម្បីតែបងខ្ញុំឈើ ខ្ញុំមិនប៉ានចេញទៅសួរសុខទុក្ខគាត់ផងបាទ។ ដោយធ្វើដោយឯកចិត្ត គឺខ្ញុំគ្មានទេ។ ខ្ញុំមិនប៉ានសុំច្បាប់គេទេ ពីព្រោះកុំឲ្យវាចោលការងារដែលអង្គការដាក់ឲ្យហ្នឹង។ បាទ សូមបញ្ជាក់ជូនប៉ុណ្ណឹងចុះបាទ។

[១១:៣៦:៥៧]

**ស៖** សូមអរគុណលោកសាក្សី។ អ៊ីចឹងមានន័យថា លោកមិនអាចដើរហើរដោយសេរីទេនៅក្នុងទីក្រុង ឬក៏ទៅតាមខេត្ត តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ មិនមែនយើងចេះតែដើរដោយចិត្តបានទេបាទ។

**ស៖** សូមអរគុណ។ លោកបានឆ្លើយថា ទូរស័ព្ទរបស់លោក គឺអាចទាក់ទងបានតែកន្លែងបីទេ មន្ទីររបស់ ខៀវ សំផន មន្ទីរ ក-១ ។ល។ តើលោកដឹងទេហេតុអ្វីបានជាលោកអាចទាក់ទងបានតែកន្លែងបីហ្នឹង?

**ឆ៖** បាទ ពីព្រោះខ្សែទូរស័ព្ទតមកកន្លែងខ្ញុំគឺជា ទូរស័ព្ទមានខ្សែ អ៊ីចឹងមិនមែនអត់ខ្សែដូចឥឡូវទាក់ទងឯណាក៏បានតាមចិត្តនោះទេ។ គឺខ្សែហ្នឹង គឺគេទាក់ទង *ឌីរិច* មកកន្លែងខ្ញុំតែម្តង។ អ៊ីចឹងមូលហេតុដែលគេដាក់ទូរស័ព្ទមកកន្លែងខ្ញុំ គឺដើម្បីសម្រួលការងារដែលគេត្រូវឆ្លើយឆ្លងគ្នា ស្រួលត្រូវបញ្ហា ហើយឧទាហរណ៍ថា ខ្ញុំមានសារទៅខាង ក-១៨ ឧទាហរណ៍ថា សារហ្នឹងប្រញាប់ ប៉ុន្តែខ្ញុំបកប្រែមិនទាន់ហើយទេ តែវាដល់ម៉ោងគេឡើងទាក់ទងគ្នា។ អ៊ីចឹងខ្ញុំសុំឲ្យអស់លោកទាក់ទងហ្នឹងកុំអាលផ្តាច់គ្នា សុំរង់ចាំខ្ញុំដើម្បីខ្ញុំចាត់ចែងទៅឲ្យបាន។ អ៊ីចឹងឧបមាថាឲ្យរង់ចាំមួយភ្លែត ១០នាទី ៥នាទីអីកុំអាលផ្តាច់ការទាក់ទងហ្នឹង។ អានេះជាមូលហេតុ ដើម្បីសម្រួលការងាររវាងទាំងបីកន្លែងហ្នឹងបាទ។

[១១:៣៩:១៩]

**ស៖** សូមអរគុណលោកសាក្សី។ ឥឡូវនេះ ខ្ញុំចង់ត្រឡប់មកនិយាយអំពីតួនាទីរបស់ក្មេងៗដែលលោកទទួលបន្ទុកក្នុងការបង្ហាត់បង្រៀន ហើយនិងជាអ្នកបកទូរលេខជាមួយនឹងលោក។ តើលោកអាចបញ្ជាក់បានទេថា តើក្មេងៗទាំងអស់ហ្នឹងត្រូវបានគេរើសយកមកធ្វើការនៅភ្នំពេញនោះយ៉ាងម៉េច? ហើយអ្នកណាជាអ្នករើសក្មេងៗហ្នឹងយកមក?

**ឆ៖** បាទ ក្មេងៗទាំងអស់នោះ អង្គការដឹកនាំនៅមូលដ្ឋានគេអ្នកជ្រើសរើសមក។ ហើយដំបូងគឺគេមិនឲ្យចូលមកកន្លែងខ្ញុំផ្ទាល់ទេ។ តាមខ្ញុំស៊ើបសួរក្មេងៗហ្នឹងថា គេបានមកស្នាក់នៅមួយកន្លែង

មួយនៅតាមមាត់ទន្លេហ្នឹង តែខ្ញុំមិនដឹងកន្លែងណាទេ ហើយក៏ខ្ញុំមិនបានសួរដេញដោលក្មេងទាំងអស់នោះដែរ។ អ៊ីចឹងពេលណាក្មេងៗ គេមកជួបជុំគ្នាអស់ហើយ បានគេបញ្ជូនមកកន្លែងខ្ញុំ ដើម្បីខ្ញុំធ្វើការហ្វឹកហ្វឺន ក្មេងខ្លះមិនទាំងចេះអក្សរផង ខ្ញុំត្រូវបង្រៀនគេតាំងពីលេខ ពីអក្សរឡើងទៅបាទ។

[១១:៤០:៥៦]

**ស៖** សូមអរគុណលោក សុផង់។ តើលោកដឹងទេ ថាគេមានលក្ខណៈវិនិច្ឆ័យ ឬក៏លក្ខខណ្ឌអីច្បាស់លាស់សម្រាប់ជ្រើសរើសក្មេងៗទាំងអស់ហ្នឹងទេ?

**ឆ៖** បាទលក្ខខណ្ឌវិនិច្ឆ័យជាមូលដ្ឋាន គឺសម័យហ្នឹងគឺគេនិយមថា អ្នកណាដែលមានវណ្ណភាពល្អ ដែលជាកូនចៅប្រជាជនមូលដ្ឋាន។ នេះជាគោលការណ៍ គឺគេជ្រើសរើសមនុស្សដែលមានលក្ខណៈស្មោះត្រង់បាទ។ ហ្នឹងៗហើយចាំបាច់បំផុត គឺការស្មោះត្រង់ហ្នឹងហើយ។

**ស៖** សូមអរគុណ។ លោកបានឆ្លើយថា កុមារហ្នឹងមានអាយុពី១០ ទៅ១២ឆ្នាំ តើមានអ្នកណាម្នាក់ដែលជាអ្នកទទួលខុសត្រូវ មើលការខុសត្រូវ ឬក៏ថែទាំក្មេងៗទាំងអស់ហ្នឹង ឬក៏ពួកក្មេងៗហ្នឹងមើលថែខ្លួនឯងទេ?

[១១:៤២:២៥]

**ឆ៖** បាទ អាចរឿង១០ ហ្នឹងអាចគេសរសេរច្រឡំទេ ព្រោះខ្ញុំឆ្លើយហ្នឹង ១០, ១២ អីហ្នឹងដូច្នេះគេដាក់ថា ១០ អ៊ីចឹងតែម្តងទៅ។ ១២ ចាប់តាមពិត គឺថា១២ឆ្នាំឡើងទេ មិនមែនក្រោម១០ឆ្នាំនោះទេបាទ។ អ៊ីចឹងគឺមិនមានក្មេងដែលពិបាកក្នុងការថែទាំអីទេ គឺថាចាប់ពី១២ឆ្នាំទៅ គេក៏អាចម្ចាស់ការលើខ្លួនគេក្នុងការស្លៀកពាក់ ក្នុងការដេកនៅអី ដោយម្ចាស់ការខ្លួនគេហើយ។ ហើយខ្ញុំក៏តែងតែជួយមើលដែរ គឺចាត់ទុកដូចជាប្អូនរបស់ខ្ញុំដែរ។ ពេលគេដេកមិនចងមុង ឬមួយក៏មិនដណ្តប់ភួយអី ខ្ញុំក៏តែងតែទៅជួយថែទាំគេទាំងអស់នោះដែរ បាទ។ ហាក់ដូចជាខ្ញុំហ្នឹងជាម្តាយឪពុកទី២របស់គេដែរ។

**ស៖** សូមអរគុណលោកសាក្សី។ ខ្ញុំសូមបញ្ជាក់ថា នៅក្នុងកំណត់ហេតុទី១ របស់លោកទៅនឹងសហចៅក្រមស៊ើបអង្កេត លោកជាអ្នកឆ្លើយថាអាយុពី១០ ទៅ១២ឆ្នាំ គឺឯកសារ E3/67 សូមទោស E3/64 គឺ ERN ជាភាសាបារាំង 00411696 និងអង់គ្លេស 00334046 សូមអភ័យទោសផងខ្ញុំអត់មាន ERN ជាភាសាខ្មែរ។ ខ្ញុំសួរ -- សូមសួរសំណួរចុងក្រោយពាក់ព័ន្ធទៅនឹងក្មេងទាំងអស់នេះ តើគេមានដាក់វិន័យតឹងរ៉ឹងចំពោះក្មេងៗទាំងនេះ ដូចជាកម្មាភិបាល ឬក៏ដូចជាបុគ្គលផ្សេងទៀតទេ?

[១១:៤៤:២៨]

**ឆ៖** បាទ កន្លែងខ្ញុំហ្នឹងវាមិនមានការតឹងតែអីទេ ពីព្រោះក្មេងៗទាំងអស់នោះគេចាត់ទុកថាជាអ្នកទុកចិត្តមួយហើយ។ ក្មេងៗទាំងអស់នោះក៏មានសេរីភាព ក្នុងការរស់នៅ ក្នុងការហូបចុក ព្រោះដោយជុំវិញសាលាខ្ញុំហ្នឹងមានផ្លែឈើជាច្រើន មានដូង មានស្វាយអី គឺក្មេងៗទាំងអស់ហ្នឹង អាចបេះបរិភោគបានតាមសេចក្តីត្រូវបានការបាទ។ ខ្ញុំមិនមានហាមឃាត់ថា មិនឲ្យបេះ មិនឲ្យហូបអីទេ។ អីចឹងគឺការរស់នៅក្នុងកន្លែងហ្នឹង គឺមិនមានការគាបសង្កត់អ្វីទេ។

**ស៖** សូមអរគុណ។ តើគេមានធ្លាប់ដាក់ទណ្ឌកម្មក្មេងៗទាំងអស់ហ្នឹងទេ?

**ឆ៖** បាទ ខ្លួនខ្ញុំផ្ទាល់មិនមានការធ្វើទារុណកម្មអ្វីទេ។ បើសិនណាជាក្មេងទាំងអស់នោះ មិនខិតខំយកចិត្តទុកដាក់ មិនខិតខំធ្វើការងារ ខ្ញុំមានតែការអប់រំណែនាំឲ្យគេខិតខំប្រឹងប្រែង ដើម្បីអនាគតរបស់គេ ក៏ដូចជាដើម្បីអនាគតរបស់ប្រទេសជាតិ។ បាទ គឺការធ្វើការងារនយោបាយ ការងារសតិអារម្មណ៍ជាបញ្ហាមូលដ្ឋាន មិនមែនយកការសម្លុត គំរាមកំហែង ឬការដាក់ទណ្ឌកម្មធ្វើជាមធ្យោបាយដើម្បីអប់រំទេបាទ។

[១១:៤៦:៣៤]

**ស៖** សូមអរគុណលោកសាក្សី។ ឥឡូវនេះ ខ្ញុំចង់ត្រឡប់មកនិយាយអំពីចម្លើយរបស់លោកដែលឆ្លើយជូនសហចៅក្រមស៊ើបអង្កេត គឺជាកំណត់ហេតុទី២ គឺឯកសារ E3/67, ERN ជាភាសាបារាំង 00374933, ERN ជាភាសាអង់គ្លេស 00483966, ERN ជាភាសាខ្មែរ 00294537។ នៅក្នុងឯកសារនេះ លោកឆ្លើយថា "ពាក្យ ដកចេញ មានន័យថា គេដកចេញពីកន្លែងមួយ ឬក៏ផ្លាស់ប្តូរពីកន្លែងមួយទៅកន្លែងលត់ដំមួយទៀត។ ប៉ុន្តែខ្ញុំមិនដឹងថា គេយកទៅដាក់នៅកន្លែងណាពិតប្រាកដទេ។ ខ្ញុំដឹងតែពីធ្វើការងាររបស់ខ្ញុំ។ សូម្បីតែខ្លួនខ្ញុំ ភ័យខ្លាចគេដកចេញដែរ ព្រោះថាពេលដែលគេដក គេអាចដឹងថា ខ្លួនគេមានកំហុសអីមួយហើយ។ ចំពោះការដកចេញនៅកន្លែងខ្ញុំផ្ទាល់ ខ្ញុំអត់ដឹងទេ។ តាមខ្ញុំដឹង ដូចជាឈ្មោះ យស់ ត្រូវគេយកចេញហើយ។ គេឲ្យឈ្មោះ ភោគ មកទទួលជំនួស។ ចំណែកឈ្មោះ ប៉ង់, ថេរ នៅក-១ ខ្ញុំមិនដឹងទេ។ ប៉ុន្តែប្រហែលជាគេដកដែរ។ ចំពោះឈ្មោះ ប៊ុន ខ្ញុំមិនដឹងទេ។ ថេរ និង ប៉ង់ ខ្ញុំមិនដឹងថាអ្នកណាបាត់ខ្លួន មុនអ្នកណាទេ"។

[១១:៤៨:១១]

ឥឡូវនេះ ខ្ញុំចង់សួរសំណួរបញ្ជាក់មួយចំនួនទៅនឹងចម្លើយរបស់លោកជូនសហចៅក្រមស៊ើបអង្កេត។ ពីព្រោះថាចម្លើយនេះ ហាក់ដូចជាមានភាពចម្រូងចម្រាស់គ្នា។ ខ្ញុំជួនកាលដូចជាមិនសូវយល់

តើលោកដឹងទេថា ថេរ និង ប៉ង់ នេះត្រូវបានគេដកចេញ ឬក៏គាត់បាត់ខ្លួន? សូមលោកបញ្ជាក់ឲ្យបានច្បាស់ត្រង់ចំណុចនេះ។

**ឆ៖** បាទ កាលហ្នឹងខ្ញុំមិនដឹងថា គេបាត់ខ្លួនពីពេលណា ឬមួយគេដកចេញទៅណា ដែលចៅក្រមស៊ើបអង្កេតជជីកសួរខ្ញុំហ្នឹង គឺខ្ញុំបាននិយាយថា ខ្ញុំមិនដឹងតាំងពីដើមទីមកហើយបាទ។ ក្នុងឯកសារគឺលោកបាន -- មុនដំបូងឲ្យខ្ញុំពន្យល់តែពីរឿងដកទេ។ ខ្ញុំនិយាយន័យត្រង់អំពីការដក។ ប៉ុន្តែឃើញថាសំណួររបស់លោកដេញដោល ជជីកសួររហូតដល់ ប៉ង់ ដល់ ថេរ ដល់អីហ្នឹង។ ខ្ញុំក៏មិនដឹងថាម៉េច? គឺមិនដែលថា ខ្ញុំមិនដឹងតែប៉ុណ្ណោះបាទ។ មានចម្លើយក្នុងពាក្យបែបហ្នឹង គឺក៏មិនអាចយកជាការបានដែរ ព្រោះខ្ញុំបាននិយាយថា "ខ្ញុំមិនដឹងទៅហើយ"។ ឯរឿងគេដកដាក់ស្ពែងនៅតាមមូលដ្ឋាន ក៏មិនដឹងជាគេធ្វើយ៉ាងម៉េចពិតប្រាកដ។ ហើយខ្ញុំក៏ព្រួយបារម្ភដែលអំពីអ្វីដែល បើសិនណាជាខ្ញុំធ្វើការងារមិនបានល្អ ខ្ញុំក៏បារម្ភថា បើសិនជាគេដកចេញអីចឹងដែរ បើសិនណាមានបញ្ហាហ្នឹង។ អីចឹងខ្ញុំគិតតែខំកសាងខ្លួនឲ្យល្អ ខំឲ្យមានសីលធម៌រស់នៅល្អ ឲ្យមានវិន័យល្អ អាហ្នឹងបានធានាខ្លួនខ្ញុំថា បើខ្ញុំគ្មានកំហុសគឺច្បាស់ជាមិនត្រូវបានគេដកចេញទេ។ អាហ្នឹងគឺចង់និយាយថាការព្រួយបារម្ភ គឺបារម្ភគឺថា សំខាន់គឺខំកសាងខ្លួនពង្រឹងអត្តនោម័តិខ្លួនឯងនេះឲ្យល្អ ឲ្យរឹងមាំ។ នេះជាកត្តាកំណត់នៅពេលនោះបាទ។

**ស៖** សូមអរគុណលោក នង សុផង់ ចំពោះការឆ្លើយបញ្ជាក់នេះ។ ក្រៅពី ថេរ និងប៉ង់ ពីព្រោះលោក លោកបានឆ្លើយថាលោកក៏ភ័យខ្លាចដែរ ខ្លាចគេដកចេញនៅពេលដែលលោកបំពេញការងារមិនបានល្អនោះ។ តើលោកមានសង្កេតឃើញទេថា មានអ្នក -- តើមានអ្នកណាដែលបាត់ខ្លួន? តើវាជារឿងធម្មតាទេនៅពេលដែលមានការបាត់ខ្លួននៅជុំវិញលោកនោះ តើអីចឹងទេ?

[១១:៥១:៤១]

**ឆ៖** បាទ ខ្ញុំដឹងថា ពេលបាត់ខ្លួន យស់ ហ្នឹង ហើយគេឲ្យ ភោគ ទៅធ្វើប្រធានមន្ទីរនៅក-១៨វិញ រឿងហ្នឹងក៏វាទាញអារម្មណ៍ឲ្យខ្ញុំមានការចាប់អារម្មណ៍ដែរ ពីព្រោះពីមុនមកខ្ញុំធ្លាប់ទូរស័ព្ទអីជាមួយ យស់ ក៏ប៉ុន្តែឥឡូវអ្នកដែលទទួលប្រធានមន្ទីរក-១៨ថ្មីនៅក្នុងឆ្នាំ៧៨ហ្នឹង គឺឈ្មោះ ភោគ អ្នកថ្មីហ្នឹង។ អីចឹងគឺការបាត់ យស់ នេះក៏ជាសញ្ញាមួយឲ្យខ្ញុំមានការបារម្ភក្នុងអារម្មណ៍របស់ខ្ញុំដែរ។ ព្រោះធម្មតា វាច្បាស់ជាមានបញ្ហាអីហើយបានជាបាត់អីចឹង បើមិនធម្មតាគេមិនអាចយក ភោគ ទៅធ្វើជាប្រធានជំនួស យស់ នោះទេបាទ។ នេះគឺជាការកត់សម្គាល់របស់ខ្ញុំនៅពេលនោះ។

**ស៖** សូមអរគុណលោក។ ឥឡូវនេះ ខ្ញុំចង់ត្រឡប់មកនិយាយអំពីគណៈ៨៧០ ហើយចង់ដឹងថា គណៈនេះជាគណៈអ្វី? នៅក្នុងចម្លើយទាំងពីរលើករបស់លោកជូនសហចៅក្រមស៊ើបអង្កេតក៏ដូចជានៅក្នុងសវនាការនេះផងដែរ លោកបាននិយាយអំពីគណៈ៨៧០ ហ្នឹងជាច្រើនលើកច្រើនសា ក៏ប៉ុន្តែខ្ញុំហាក់ដូចជាមិនសូវបានយល់ច្បាស់អំពីនិយមន័យនៃគណៈ៨៧០ នេះ ជួនកាលលោកថាជាគណៈអចិន្ត្រៃយ៍ ចួនកាលលោកថាគណៈមជ្ឈិម។ ដូច្នេះតើលោកអាចពន្យល់ឲ្យបានច្បាស់ទេថា តើគណៈទាំងពីរហ្នឹងខុសគ្នាយ៉ាងម៉េចដែរ គណៈមជ្ឈិម និងគណៈអចិន្ត្រៃយ៍ហ្នឹង?

[១១:៥៣:៥៥]

**ឆ៖** បាទ អស់លោកសុទ្ធតែធ្លាប់ធ្វើការធំៗរហូតដល់ផ្នែកអង្គការសហប្រជាជាតិ សូម្បីតែនៅក្នុងអង្គការសហប្រជាជាតិក៏មានសមាជិកអចិន្ត្រៃយ៍ដូចគ្នាអ៊ីចឹងដែរបាទ។ អ៊ីចឹងខ្ញុំមិនអាចពន្យល់លោកថែមទៀតទេបាទ។

**ស៖** ខ្ញុំមិនដឹងថាមានបញ្ហាបកប្រែ ឬក៏យ៉ាងណា ខ្ញុំព្យាយាមចង់បានពន្យល់អំពីលោក នៅក្នុងចម្លើយរបស់លោក ខ្ញុំនឹងពិនិត្យមើលទៅលើកំណត់ហេតុរបស់លោក លោកបាននិយាយអំពីគណៈអចិន្ត្រៃយ៍ និងគណៈមជ្ឈិម, មជ្ឈិម និងអចិន្ត្រៃយ៍។ ហើយលោកបញ្ជាក់ថា គណៈ៨៧០ ជួនកាលជាគណៈមជ្ឈិម ជួនកាលជា គណៈអចិន្ត្រៃយ៍។ ដូច្នេះ ខ្ញុំចង់ដឹង ថាតើគណៈមជ្ឈិម និងគណៈអចិន្ត្រៃយ៍ និងគណៈ៨៧០ ហ្នឹង ជាគណៈតែមួយទេឬ?

**ឆ៖** បាទ រឿងគណៈហ្នឹង ខ្ញុំៗមិនច្បាស់ហ្នឹងហើយ បានខ្ញុំមិនដាក់លាក់នឹងខ្លួនឯងផង មិនដឹងពីព្រោះថា ឃើញតែរបាយការណ៍គេដាក់អ៊ីចឹង។ ជួនកាល គេដាក់ថា "អង្គការ៨៧០" ជួនកាល គេដាក់ "គណៈ៨៧០" ជួនកាលស៊ីញ៉េពីក្រោម គេដាក់ថា "៨៧០" ទទេហ្នឹងក៏មាន។ អ៊ីចឹង ធ្វើឲ្យខ្ញុំពិបាកក្នុងការជម្រាបជូនអង្គសវនាការឲ្យបានច្បាស់លាស់លើបញ្ហានេះ វាពិបាកនឹងចំណាំណាស់បាទ។ ខ្លួនខ្ញុំផ្ទាល់ក៏មិនដឹងដែរបាទ។

**ស៖** សូមអរគុណ។ ដើម្បីឲ្យច្បាស់នោះ ចំពោះលោក គឺគណៈ៨៧០, គណៈមជ្ឈិម, គណៈអចិន្ត្រៃយ៍ គឺដូចគ្នាទេ តែមួយទេ មែនទេចំពោះលោកហ្នឹង គឺជាអង្គភាពតែមួយទេ តើអ៊ីចឹងទេ?

**លោក ម៉ៃខល កាណាវាស៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតលោកប្រធាន។ ការកំណត់អំពីអ្វីដែលសាក្សីផ្តល់សក្ខីកម្ម គឺមិនគួរធ្វើឡើងទេ អ្វីដែលសាក្សីនិយាយថាម៉េច គួរបែបនេះ។ ដូច្នេះ អានេះគឺជាយើងផ្អែកទៅលើអ្វីដែល

គាត់បានឆ្លើយកាលពីមុនរួចមកហើយ។ ដូច្នេះ ខ្ញុំគិតថា គួរតែមេធាវីគាត់បន្តទៅមុខទៀត ដោយមិនចាំបាច់បញ្ជាក់អីបន្ថែមនោះទេ។

[១១:៥៧:០៣]

**ប្រធានអង្គជំនុំ៖**

សាក្សីមិនចាំបាច់ឆ្លើយតបនឹងសំណួរនេះទេ។

**សួរដោយកញ្ញា ហ្វីលីពីន ស៊ុតហ្វ៖**

**ស៖** លោក នង សុផង់ ឥឡូវនេះ ខ្ញុំចង់ចោទសួរលោកនូវសំណួរមួយចំនួន ពាក់ព័ន្ធទៅនឹងលោក នួន ជា។ ខ្ញុំសូមយោងទៅលើកំណត់ហេតុស្តាប់ចម្លើយទីមួយរបស់លោក ដោយសហចៅក្រមស៊ើបអង្កេត។ នៅក្នុងកំណត់ហេតុស្តាប់ចម្លើយទី១នោះ លោកបញ្ជាក់ថា -- សូមទោស គឺគេបានបង្ហាញជូនលោកនូវទូរសារមួយចំនួន ហើយសហព្រះរាជអាជ្ញាកាលពីម្សិលមិញ ក៏បានបង្ហាញជូនលោកដែរ គឺទូរលេខ១៥ គឺ E3/1679 ហើយនិងទូរលេខ៥៤ ដែលមានលេខ E3/73។ នៅពេលដែលសហចៅក្រមស៊ើបអង្កេតសួរលោកពាក់ព័ន្ធទៅនឹងទូរលេខទាំងអស់នោះ ហើយគេសួរសំណួរថា“ហេតុអ្វីបានជាមានចម្លងជូន នួន ជា នៅក្នុងទូរសារនោះ?”។ លោកឆ្លើយថា “នួន ជា ទទួលខុសត្រូវខាងប្រជាជន បានន័យថា គាត់ទទួលបន្ទុកខាងប្រជាជន”។ តើលោកអាចពន្យល់ឱ្យបានច្បាស់បន្តិចទេ តើពាក្យថា នួន ជា ទទួលបន្ទុកខាងប្រជាជនហ្នឹង តើមានន័យថាម៉េច? តើគាត់ទទួលខុសត្រូវអីខ្លះខាងប្រជាជនហ្នឹង?

[១១:៥៨:៤១]

**លោក នង សុផង់៖**

**ឆ៖** បាទ នៅចំពោះលោក នួន ជា គេបានប្រកាសជាចំហ ថាលោកជាធ្វើការ ក្នុងស្ថាប័នសភាតំណាងប្រជាជន ហើយលោកក៏មានតួនាទីជាប្រធាននៅក្នុងស្ថាប័នហ្នឹង។ អ៊ីចឹង ក្នុងឋានៈលោកជាតំណាងប្រជាជន បានន័យថា អ្វីៗដែលទាក់ទងនឹងប្រជាជនហ្នឹង គឺព្រោះលោកជាតំណាងកំពូលលើគេហើយ ដូច្នេះគឺលោកក៏មានភារកិច្ចទទួលខុសត្រូវចំពោះមុខ ជាតំណាងរបស់ប្រជាជនដែរ បាទ។

**ស៖** សូមអរគុណលោក នង សុផង់។ ឥឡូវនេះ ខ្ញុំយោងទៅលើចម្លើយមួយទៀតរបស់លោក គឺឯកសារ E3/64។ ERN ជាភាសាបារាំង 00411708, ERN ជាភាសាអង់គ្លេស 00334058, ERN ជាភាសាខ្មែរ 0032804។ លោកបាននិយាយអំពីបញ្ហាផ្ទៃក្នុង ហើយនិងការខុសសីលធម៌នោះ គឺស្ថិត

នៅក្រោមការគ្រប់គ្រងរបស់ នួន ជា ហើយលោកបានបញ្ជាក់ថា "ការខុសសីលធម៌ហ្នឹងមានន័យថា ការរំលោភផ្លូវភេទ" តើលោកអាចបញ្ជាក់បានទេថាលោកធ្លាប់ជួបទូរលេខច្រើនទេ ដែលនិយាយអំពី ការខុសសីលធម៌ ហើយនិងការរំលោភផ្លូវភេទនេះ?

**ឆ៖** បាទ ទូរលេខដែលនិយាយពីខុសសីលធម៌គឺខ្ញុំបានឃើញដូចជាអស់លោកបានឃើញដូចគ្នាដែរ គឺមកពីខាងមណ្ឌលគិរីបាទ គឺខ្ញុំបានឃើញតែអាមួយហ្នឹងដែរ។ នៅក្នុងសម័យនុ៎ងគឺថា បើគេរាយ-ការណ៍ថា ប៉ះពាល់សីលធម៌ វាច្បាស់ជាមានការប៉ះពាល់ខាងការរំលោភផ្លូវភេទលើនារីភេទហើយបាទ។ នេះចង់បញ្ជាក់អំពីរឿងខុសសីលធម៌ គឺឲ្យអង្គសវនាការបានយល់អំពីន័យរបស់វាហ្នឹងបាទ។

[១២:០២:១០]

ឯមកពីផ្សេងៗទៀតដូចអត់មានឃើញទេ អត់មានរបាយការណ៍អី ដែលចំពោះមុខសញ្ញាដែលខ្ញុំទទួលគឺ ឃើញតែប៉ុន្នានដូចអស់លោក លោកស្រីបានឃើញស្រាប់។

**ស៖** សូមអរគុណលោកសាក្សី។ ខ្ញុំជិតបញ្ចប់ហើយ ក៏ប៉ុន្តែឥឡូវនេះខ្ញុំត្រឡប់មកនិយាយអំពីកំណត់ហេតុស្ដាប់ចម្លើយរបស់លោក គឺកំណត់ហេតុលើកទី២ ដែលលោកបានឆ្លើយទៅនឹងសហចៅក្រមស៊ើបអង្កេតគឺឯកសារ E3/67។ ERN ជាភាសាបារាំង 00374935, ERN ជាភាសាអង់គ្លេស 00483968, ERN ជាភាសាខ្មែរ 00294538 -- 39 (សូមអភ័យទោស)។ នៅក្នុងឯកសារនេះ លោកបានឆ្លើយអំពីឈ្មោះ ខាំ មី លោកបានឆ្លើយថា "នៅក្រោមគណ:៨៧០ នោះមានអង្គភាពកងទ័ពមួយដែលដឹកនាំដោយលោក ខាំ មី ដែលបានធ្វើពលីកម្មនៅសមរភូមិនៅឆ្នាំ៧៨-៧៩។ ក-១ ជាកន្លែងធ្វើការរបស់ ប៉ុល ពត ហើយ ក-៣ ប្រហែលជាកន្លែងធ្វើការរបស់ ខៀវ សំផន។ នៅក្រោម៨៧០ ខ្ញុំដឹងថា ស-៧១ និងកងទ័ពមួយដឹកនាំដោយលោក ខាំ មី ផ្ទាល់"។ លោក នង សុផង់ តើលោកអាចបញ្ជាក់ឲ្យបានច្បាស់បន្តិចទេ ថាលោក ខាំ មី ហ្នឹងជាអ្នកណា? ហើយគាត់មានតួនាទីអ្វីដែរ?

[១២:០៤:១៤]

**ឆ៖** បាទលោក ខាំ មី គឺជាមាន ជាជនជាតិ នៅភូមិភាគឦសាន តែឈ្មោះដើមពិតរបស់លោកយ៉ាងណា ខ្ញុំមិនដឹងទេ។ គឺគេហៅថា ខាំមីៗ អ៊ីចឹងតែម្ដង។ គាត់ជាអ្នកដឹកនាំទ័ពមួយ កងទ័ពមួយដែលមានទីស្នាក់ការនៅក្បែរសាលាខ្ញុំហ្នឹងដែរបាទ។ ទីស្នាក់ការបញ្ជាការរបស់លោកនៅក្នុងបរិវេណជាប់នឹងសាលារបស់ខ្ញុំដែរ។ ហើយលោកនេះ ក៏ជាអង្គភាពមួយដែលនៅក្រោមការដឹកនាំរបស់ ស-៧១ ផង និងក្រោមការដឹកនាំរបស់៨៧០ ផ្ទាល់ផង។ ពេលដែលមានភ្ញៀវអីផ្សេងៗ គឺលោកចាត់ចែងកងទ័ព

របស់លោក ខាំ មី ហ្នឹងហើយជាអ្នកការពារសន្តិសុខ។ នេះសូមបញ្ជាក់ជូនប៉ុណ្ណឹងបាទ។

**ស៖** សូមអរគុណលោកសាក្សី តើលោកដឹងឈ្មោះអង្គភាពយោធាដែរទេ តើមានកូដអីសម្គាល់ឈ្មោះអង្គភាពយោធាដែលដឹកនាំដោយ ខាំ មី ទេ?

**ឆ៖** បាទ ខ្ញុំមិនដឹងទេបាទ។ មិនដឹង មិនស្គាល់ទេបាទ។

**ស៖** តើលោកធ្លាប់ឮឈ្មោះអង្គភាព យ-១០ ទេ?

**ឆ៖** បាទ ឮគេនិយាយដែរ តែខ្ញុំមិនច្បាស់ក្នុងខ្លួនឯងថា -- ព្រោះខ្ញុំមិនច្បាស់ ខ្ញុំសូមមិននិយាយបាទ។

[១២:០៦:៤០]

**ស៖** សូមអរគុណលោកសាក្សី។ ដូច្នេះ មានន័យថា លោកមិនអាចដឹងទេថា យ-១០ ហ្នឹងជាអង្គភាពយោធាដែលដឹកនាំដោយ ខាំ មី នោះ តើអ៊ីចឹងដែរទេ?

**ឆ៖** បាទ ពិតប្រាកដមែន ព្រោះមិនដឹងជាគេកំណត់អង្គភាព។ សូម្បីតែអង្គភាពកប៉ុន្មានជុំវិញ ស-៧១ នេះក៏ខ្ញុំរៀបរាប់មិនបានអស់ដែរបាទ ព្រោះខ្ញុំស្គាល់មិនអស់។ អ៊ីចឹងរហូតទៅដល់យោធាទៀតខ្ញុំកាន់តែមិនយល់ មិនដឹងទៀតហើយ។

**ប្រធានអង្គជំនុំ៖**

លោកស្រីមេធាវី តើមានប៉ុន្មានសំណួរទៀត ពេលវេលាម៉ោងដប់ពីរប្រាំនាទីហើយ?

**កញ្ញា ហ្វីលីពីន ស៊ុតហ្ស៍៖**

លោកប្រធាន ខ្ញុំបញ្ចប់ការសួរសំណួរហើយ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទអរគុណ អរគុណសាក្សី។ កិច្ចដំណើរការសវនាការនៅព្រឹកនេះដល់ពេលត្រូវសម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃ អំ! សម្រាប់ព្រឹកនេះត្រឹមនេះ សវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែក ថ្ងៃពុធ ទី០៥ ខែកញ្ញា ឆ្នាំ២០១២ ដោយចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក។ ហើយអង្គជំនុំជម្រះសូមរំឭក និងបញ្ជាក់សាជាថ្មីម្តងទៀត ថាអង្គជំនុំជម្រះមិនធ្វើសវនាការទេ ដោយមូលហេតុអង្គជំនុំជម្រះមានការងារជាបន្ទាន់មួយចំនួនចាំបាច់ត្រូវប្រជុំពិភាក្សាសម្រេច។ ហើយសវនាការនៅថ្ងៃស្អែកនេះ អង្គជំនុំជម្រះនឹងបន្តស្តាប់សក្ខីកម្មសាក្សី នង សុផង់ ដែលនឹងបន្តតាំងសំណួរដេញដោលដោយក្រុមមេធាវីការពារក្តី ដែលនឹងចាប់ផ្តើមពីក្រុមមេធាវីការពារក្តីលោក ខៀវ សំផន មុនក្រុម

មេធាវីការពារក្តីពីរក្រុមទៀត។ សូមភាគី និងសាធារណជនជ្រាប។

[១២:០៨:៤៧]

លោក នង សុផង់ ការស្តាប់សក្ខីកម្មរបស់លោកនៅមិនទាន់ចប់នៅឡើយទេ។ សវនាការត្រូវបន្តធ្វើនៅថ្ងៃស្អែកទៀត។ ដូច្នេះ អង្គជំនុំជម្រះសូមអញ្ជើញលោកមកបន្តផ្តល់សក្ខីកម្មនៅថ្ងៃស្អែកទៀតដោយចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក។

មន្ត្រីរដ្ឋបាលតុលាការ សម្របសម្រួលជាមួយនឹងមន្ត្រីអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ក្នុងការជូនសាក្សីនេះវិលត្រឡប់ទៅកាន់កន្លែងដែលគាត់ស្នាក់នៅវិញ ហើយនិងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញនៅព្រឹកថ្ងៃស្អែក នៅវេលាម៉ោងប្រាំបួន។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងបីរូបត្រឡប់ទៅមន្ទីរឃុំឃាំងនៃអ.វ.ត.កវិញចុះ ហើយឲ្យនាំខ្លួនពួកគាត់ត្រឡប់មកកាន់បន្ទប់សវនាការនេះវិញនៅព្រឹកថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួន។

សម្រាកចុះ៕

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង១២:០៩ នាទី)*